# ទស្សនៈរបស់សូក្រាត (៤៦៩-៣៩៩ មុន គ.ស.)

## ជីវប្រវត្តិរបស់សូក្រាត



សូក្រាត (SOCRATE) កើតនៅក្នុងឆ្នាំ ៤៦៩ មុន គ.ស. ក្នុងតំបន់អូឡាំព្យ៉ាដ ទីក្រុងអាតែននៃប្រទេសក្រិចគឺកើតក្រោយ សង្គ្រាមនៅសាឡាមីន ១០ ឆ្នាំ ។ គាត់បានទទួលមរណកាលនៅឆ្នាំ ៣៩៩ មុន គ.ស. ក្នុងតំបន់អូឡាំព្យ៉ាដ ទីក្រុងអាតែន ក្នុងជន្មាយុ ៧០ ឆ្នាំ ។

សូក្រាត គឺជាទស្សនវិទូម្នាក់ដែលប្រកបដោយបញ្ញាវាងវៃ និងឈ្លាសវៃឆ្លាត ព្រមទាំងមានជីវិតពោរ ពេញ ទៅ

ដោយសីលធម៌ជាងគេបំផុត ។ ឪពុកឈ្មោះ សូប្រូស៊ីន ដែលមានមុខរបរជាជាងចម្លាក់ថ្ម ម្ដាយ ឈ្មោះ ហ្វារ៉ាណែត មានមុខរបរជាឆ្មប ។ ដូច្នេះហើយ បានជាសូក្រាតតែងនិយាយថា «ម្ដាយខ្ញុំជាឆ្មបសំរាលកូន ឯខ្ញុំជាឆ្មបសំរាយគំនិត» ។

## លក្ខណៈទូទៅរបស់សូក្រាត

លោកសូក្រាត (៤៦៩-៣៩៩) មុន គ.ស. គាត់បានក្លាយជាអ្នកទស្សនវិជ្ជាម្នាក់ដែលសំខាន់ និងល្បី ល្បាញ នៅក្នុងប្រវត្តិសាស្ត្ររបស់ពិភពលោក ។គាត់ត្រូវបានរដ្ឋាភិបាលក្រុងអាតែន ដែលគ្រង ប្រទេសខ្លួននាពេលនោះ តាមរបបប្រជាធិបតេយ្យបែបផ្ទាល់បានចោទប្រកាន់គាត់ថាគាត់មិន បាន គោរពដល់ព្រះរបស់ទីក្រុង នាសម័យនោះ ហើយនឹងបានផ្សព្វផ្សាយនូវជំណឹងអកុសល ផ្សេងៗទៀតហើយថែមទាំងបានបំផ្លាញដល់អនាគតរបស់យុវជន ។ នៅពេលនោះរដ្ឋាភិបាល យល់ថាផ្នែកនយោបាយពុំមានទោសកំហុសអ្វីទេ ចំណែកឯបញ្ហាសាសនាវិញស្ថិតក្រោម សមត្ថ កិច្ច របស់រដ្ឋ ។ លោកសូក្រាតបានបង្រៀនថា «នយោបាយគឺជាសិល្បៈដែលទាមទារឲ្យមាននូវ ចំណេះដឹងជាមូលដ្ឋានដ៏ល្អ» ។

ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមនោះ មានប្រជាជនភាគច្រើនរាប់បញ្ចូលទាំងអ្នក នយោបាយនាសម័យនោះពុំមានចំណេះដឹងជាមូលដ្ឋានល្អនោះឡើយ ហើយជាហេតុ ធ្វើឲ្យពួក គេពុំអាចដោះស្រាយនូវបញ្ហានយោបាយបានល្អទេ។ ទស្សនៈខាងលើនេះវាប្រឆាំងទៅនឹងគំនិត ប្រជាធិបតេយ្យរបស់អាតែន ដែលត្រូវការចាំបាច់នូវសំឡេងមនុស្សគ្រប់រូបត្រាប់តាមមាត់របស់ពួកគេដូចៗគ្នា ។ ហើយនៅពេលនោះសូក្រាតបានទាក់ទង នឹងពួកគណាធិបតេយ្យ ដែលកាន់អំណាចនៅក្រុងអាតែនក្នុងកំឡុងឆ្នាំ ៤១១ មុន គ.ស ហើយឆ្នាំ ៤០៤-៤០៣ មុន គ.ស. ហើយកិច្ចការរបស់ពួកគណាធិតយ្យ (Oligarchy) នេះត្រូវបាពួករាជាធិបេតយ្យ (Monarchy) នាពេលនោះគិតថាមានគ្រោះថ្នាក់បំផុត ។ មួយចំនួននៃពួកនេះមានពីរបីនាក់ធ្លាប់ជា អតីតក្លើ របស់គាត់ពីមុន ។ ទោះជាយ៉ាងណាក៏ដោយ សូក្រាតយល់ថា ពលរដ្ឋទាំងអស់ ទោះជាក្នុង ករណីណាក៏ដោយ ត្រូវតែគោរព

បង្គាប់របស់រដ្ឋហើយមិនអាចក្បត់ងមនសិការនេះឡើយ ។ គាត់ បានប្រកែកដាច់ខាតចំពោះការជួយរូបគាត់ឲ្យរត់ចេញពីគុក ។ ហេតុផល ៣ យ៉ាងដែលគាត់ បានផ្ដល់គឺ៖

១-កិច្ចការទំនាក់ទំនងរវាងរដ្ឋ ហើយនឹងពលរដ្ឋ គឺវាមិនដូចគ្នាទៅនឹងទំនាក់ទំនងរវាង ឪពុកម្ដាយហើយនឹងកូនទេ គឺថារដ្ឋជំពាក់គុណពលរដ្ឋ ព្រោះថាពលរដ្ឋ ជាឪពុកម្ដាយរបស់រដ្ឋ ។

២-ក្នុងនាមសូក្រាត ជាអ្នកគោរពច្បាប់ម្នាក់ ហើយគាត់ជាពលរដ្ឋអាតែន គាត់បានទទួល នូវការទំនុកបំរុងនានាដើម្បី ទ្រទ្រង់ជីវិតរបស់គាត់ ដូច្នេះគាត់បានចុះហត្ថលេខាជាមួយអាតែន ថា គាត់ត្រូវតែគោរពច្បាប់អាតែន ។

៣. ការរំលោភលើច្បាប់រដ្ឋហើយ ប្រសិនបើអ្នកគ្រប់គ្រងគិតថា ត្រឹមត្រូវនោះលទ្ធិផលបាន មក វិញគឺប្រកបដោយគ្រោះថ្នាក់បំផុត ក្នុងការវិនិច្ឆ័យតាមគតិយុត្តបែបនេះ.។

## លក្ខណៈសំខាន់ៗមួយចំនួនទៀត

សូក្រាតត្រូវបានជនជាតិក្រិចទាំងអស់ប្រសិទ្ធិនាមថាជាបិតាទស្សនៈវិជ្ជា និងជាបិតាវិទ្យាសា ស្រ្តនយោបាយ។ប្រជាជនអាតែននាពេលនោះ ទទួលស្គាល់គាត់ថា ជាវាគ្មិនពូកែនិយាយពូកែ សួរពូកែឆ្លើយទីណាមានសូក្រាត ទីនោះមានមនុស្សរោម ជុំវិញ។ កិច្ចការរបស់គាត់គឺស្វែងរកការ ពិតមានសុភវិនិច្ឆ័យ សមហេតុផលមានតំលៃ មានសុជីវធម៌ សីលធម៌ ដែលកត្តាទាំងនេះជា លក្ខណៈរបស់រដ្ឋនិងច្បាប់ ។ បើមានការពិភក្សាស្ដីអំពីសីលធម៌នយោបាយ គាត់បានពន្យល់ ច្បាស់លាស់និងមានលក្ខណៈនិយមន័យ ។ លោកបានលើកពីលក្ខណៈខុសគ្នារវាងសិទ្ធិពិត និង ច្បាប់រដ្ឋ ឃើញថាចំនុចទាំងពីរនេះមានប្រភពចេញអំពី Intellector Reason ទាំងអស់ជាដំបូង ។

គាត់បានព្យាយាមធ្វើការបកស្រាយ ឆ្លុះបញ្ចាំងពីការរៀបចំប្រមូលផ្ដុំ នូវលក្ខណៈធម្មជាតិ Intellectដែលជាប្រភពមានសុជីវធម៌នៃនយោបាយ និងនៃបាតុភូតផ្សេងៗរបស់ច្បាប់ ។ ដូច្នេះ គាត់បានចេញនូវសេចក្ដីសន្និដ្ឋានថា Intellect យុត្តិធម៌ និងច្បាប់វាជាសទិសន័យនឹងគ្នា ។ សូ ក្រាត ជាមនុស្សម្នាក់ដែលគោរពច្បាប់បំផុត ព្រោះច្បាប់ជាកាតព្វកិច្ចរបស់ពលរដ្ឋគ្រប់រូប ហើយ ពលរដ្ឋត្រូវតែទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួន ។ម្យ៉ាងទៀត ការបង្ហាញឲ្យឃើញនូវភាពត្រឹមត្រូវមួយទៀត អំពីច្បាប់ និងយុត្តិធម៌គុណធម៌ព្រមទាំងអំពើល្អដែលផ្ដល់ផលប្រយោជន៍ទាំងអស់នេះ អាចចាត់ទុក ក្នុងចង្កោមដែលមានមូលដ្ឋានពីចំណេះដឹង និងការអប់រំល្អ ។

ទស្សនៈខុសគ្នាអំពីសុជីវធម៌ច្បាប់នយោបាយ ហើយនឹងការអនុវត្តន៏ជាក់ស្តែង របស់ រដ្ឋាភិ បាល ហើយមិនមែននៅតែក្នុងរបបប្រជាធិបតេយ្យ (Democracy) ប៉ុណ្ណោះទេ សូម្បីតែនៅក្នុង របបគណាធិបតេយ្យ (Oligarchy) របបទុជនាធិបតេយ្យ (Tyranny) អភិជនាធិបតេយ្យ (Aristocracy) ផងដែរ ។សូក្រាត បានតិះទៀន នូវរាល់កំហុសទាំងឡាយរបស់រដ្ឋដែលគ្មាន ភាព សច្ចះបង្ហាញពីហេតុផលឲ្យបានច្បាស់លាស់ឡើយ ។ ចំណោកឯទស្សនៈទ្រឹស្តីនយោបាយវិញការបកស្រាយរបស់សូក្រាតពុំមានលក្ខណៈដូចទៅ នឹងការបកស្រាយរបស់អ្នកប្រាជ្ញដទៃទៀតឡើយ ។ រដ្ឋដែលរីកចម្រើន គឺដោយសារច្បាប់ដឹកនាំ ។គាត់បានឲ្យតំលៃយ៉ាងខ្លាំងរបស់ពួកអភិជនា ធិបតេយ្យ(Aristocracy) ហើយបដិសេធនូវការដឹកនាំ បែបប្រជាធិបតេយ្យជ្រុល ដែលជាកត្តាធ្វើ ឲ្យ ប្រទេសជាតិជួបនូវវិបត្តិ ជាច្រើនរហូតរលាយដល់រដ្ឋាភិបាលនោះតែម្តង ។

សូក្រាតឃើញភាពអសមត្ថភាពរបស់មេដឹកនាំប្រជាធិបតេយ្យនាសម័យនោះ ។ អ្នកដឹក នាំត្រូវ តែមាននូវចំណេះដឹងយល់ដឹងច្រើន ហើយការទាមទារនេះ គឺគំនិតចំបងរបស់សូក្រាត ស្តីអំពី សុភវិនិច្ឆ័យរបស់រដ្ឋាភិបាលនិងសិទ្ធិ ជាកត្តាចាំបាច់ដំបូងដែលមានការពាក់ព័ន្ធ ចាំបាច់ទៅគ្រប់ ទម្រង់គ្រប់គ្រងនយោបាយទាំងអស់ ស្តេចទាំងឡាយនិងអ្នកដឹកនាំទាំងឡាយ ត្រូវមានលក្ខណៈ ចាំបាច់ជាច្រើនដូចខាងលើមិនមែនសំដៅទៅលើតែមនុស្សពាក់មកុដនិង គ្រឿងអលង្ការពេញខ្លួន ឬមិនមែនសំដៅទៅលើ តែមនុស្សដែលគេជ្រើសរើស ដោយសារមានទ្រព្យសម្បត្តិច្រើន ឬឬកពាខ្ពស់សមរម្យ ឬមិនមែនសំដៅទៅលើមនុស្ស ដែលបាន អំណាចដោយសារកម្លាំងអាវុធនិងអំពើហិង្សាពូកែភូតភរនោះទេ ក៏ប៉ុន្តែចាំបាច់ត្រូវការអ្នកមានសមត្ថភាដឹកនាំនិងគ្រប់គ្រង ។ការតិះទៀនគំនិតនយោបាយស្តីអំពីចំណេះដឹង ក្នុងការដឹកនាំដែលត្រូវមាន នោះបានងាក ចេញឆ្ងាយអំពីគោលការណ៏នានា របស់ប្រជាធិបតេយ្យ ពួកគហបតីរបស់ពួកអេលីត និងរបស់ ពួក ផ្តាច់ការ ។ សូក្រាតតិះទៀនរបបផ្តាច់ការខ្លាំងជាងគេបំផុត ។ ក្នុងគំរោងនៃគំនិតនយោបាយរបស់សូក្រាតបានបង្ហាញនូវភាពមានសមត្ថភាពក្នុងការ ដឹកនាំ ចេះវិធីសាស្រ្ត និងចំណេះដឹង ដែលចាំបាច់សម្រាប់ដឹកនាំ ពោលគឺគោលការណ៏សំខាន់ៗ ទាំង អស់នៃសមត្ថភាព នៃការគ្រប់គ្រងមិនតែប៉ុណ្ណោះ នៅក្នុងគំរោងគំនិតនយោបាយ បានព្យា យាមពន្យល់ទ្រឹស្តីខ្លះនិងបង្កើតនូវមូលដ្ឋាន នៃសុជីវវិនិច្ឆ័យ ហើយនឹងខ្លឹមសាររបស់រដ្ឋ ។ ដោយ មានជំនឿជឿជាក់លើគំនិត និងចំណេះដឹងរបស់ខ្លួន ស្គាល់ច្បាស់ថាអ្វីជាយុត្តិធម៌ជាច្បាប់ ហើយនឹងធ្វើជាគំនិតសុភវិនិច្ឆ័យ ក្នុងការដឹកនាំគ្រប់គ្រង ចំណែកសូក្រាត ជាច្រើនលើកច្រើន

សារ ធ្លាប់ បានប្រឈមមុខគ្នា ជាមួយរដ្ឋអំណាច (ដូចរដ្ឋអំណាចប្រជាធិបតេយ្យ បែបផ្ទាល់ និងរដ្ឋអំណាច ផ្តាច់ការ) ក្នុងគោលបំណងព្យាយាមបញ្ចូល នូវឥទ្ធិពលទៅលើគូបដិបក្ស និងបញ្ចូលនូវនយោ បាយតិះទៀន ដ៏ល្បីល្បាញរបស់គាត់ ។ ក៏ប៉ុន្តែចុងបញ្ចប់សូក្រាតត្រូវតែផឹកថ្នាំពិស ។ ការកាត់ ទោសសូក្រាត ដោយមេដឹកនាំក្រុងអាតែនដែលកាន់របបប្រជាធិបតេយ្យបានចោទប្រកាន់ ថាគាត់មិនជឿព្រះ មិនគោរពច្បាប់ និងបំផ្លាញអនាគតយុវជន ។ ការកាត់ទោស ប្រហារជីវិត ពុំបាន ធ្វើឲ្យសូក្រាតតក់ស្លុតឡើយ ផ្ទុយទៅវិញគាត់នៅតែមានជំនឿទៅលើគោលការណ៍របស់គាត់ មិនរំលោភច្បាប់ មិនធ្វើអ្វីដែលឆ្លើយតបនឹងភាពគ្មានយុត្តិធម៌ដោយអំពើអយុត្តិធម៌ឡើយ ហើយ គាត់បានបដិសេធចំពោះការជួយគាត់ឲ្យរត់ចេញពីគុក ។

មរណៈភាពរបស់សូក្រាតបានលេច ឡើងនូវចំណោទជាច្រើនរាប់មិនអស់ ស្តីអំពីការគំរាម គំហែងដល់បញ្ញាវន្ត ដែលកំពុងតែចូលរួមក្នុងកិច្ចការនយោបាយ ។ ទ្រឹស្តីរបស់សូក្រាត ជីវិត របស់ គាត់និងមរណៈភាពរបស់គាត់បានធ្វើឲ្យមានការចាប់អារម្មណ៍ជាខ្លាំងផងដែរ មកលើអ្នក ប្រាជ្ញ ដែលទទួលស្គាល់ស្នាដៃនិងគំនិតរបស់គាត់ជំនាន់ក្រោយៗ ថែមទាំងបាន ជះឥទ្ធិពល យ៉ាងខ្លាំង ទៅលើទំព័រប្រវត្តិទស្សនវិជ្ជា និងគំនិតនយោបាយ ។ ឥទ្ធិពលសូក្រាតបានសម្តែង ឡើង នូវជ័យជំនះដ៏ធំធេងរបស់គាត់ ក៏ដូចជារបស់ប្រជាជនក្រិចទាំងមូល ស្តីអំពីគំនិតនយោ បាយ និងច្បាប់ ដូចជាទស្សនៈនយោបាយរបស់ ផ្លាតូ ហើយនឹងនយោបាយវិទ្យា របស់លោក អារីស្តូត ៕

# វិធីសាស្ត្របង្រៀនរបស់សូក្រាត



សូក្រាត មានវិធីបង្រៀនពីរយ៉ាងគឺ សិល្បៈបង្កើតគំនិត និងការចំអក ។ សូក្រាត ប្រើវិធីបង្កើត គំនិត ចំពោះមនុស្សសាមញ្ញ ដែលមិនចេះអួតអាង ហើយដឹងថាខ្លួនគ្មានចេះអ្វីសោះ ។ សូក្រាត ប្រើវិធីចំអកចំពោះពួកសូហ្វិស (ពួកទស្សនវិជ្ជាមួយក្រុមដែលប្រឆាំងនឹងទស្សនវិជ្ជារបស់ សូក្រា ត) ពួកនេះអួតអាងមានជំនឿថា ខ្លួនមានចំណេះជាសកល ។ ឃ្លាចំបងរបស់សូក្រាតស្ដីពីទស្សន វិជ្ជាគឺ «ខ្ញុំដឹងតែមួយមុខគត់ គឺគ្មានចេះអ្វីសោះ» ៕

## ទស្សនវិជ្ជារបស់សូក្រាត

-ត្រូវយល់ពីដំណើរប្រព្រឹត្តទៅនៃធម្មជាតិ ។

-ត្រូវយល់អ្វីដែលនៅជិតយើងមុននឹងយល់អ្វីដែលនៅឆ្ងាយពីយើង ។

-ត្រូវស្គាល់ខ្លួនឯងដោយខ្លួនឯង ។

-ត្រូវដុះខាត់ព្រលឹង(ចិត្ត)ឲ្យបានប្រសើរជាងដុះខាត់សរីរៈ ។

-ត្រូវនិយមប្រើពាក្យថា«ខ្ញុំមិនចេះអ្វីសោះ» ។

-ត្រូវជជែកគ្នាដើម្បីរកការពិតព្រោះការជជែកជាវិធីបង្កើតគំនិត ។

-លទ្ធផលដែលល្អជាលទ្ធផលដែលបានទទួលការរិះគន់រួចហើយ ។

សូក្រាតពោលថា «ពុំមានអ្នកណាម្នាក់ កាចដោយចេតនាទេ។ មនុស្សម្នាក់ៗសុទ្ធតែមានបំណ ងល្អ តែបើប្រែជាអាក្រក់វិញ គឺពិតជាមានបុព្វហេតុ ដូចជាបុព្វហេតុផ្ទាល់ខ្លួន ឬក្រៅខ្លួន» តែ ចំពោះប្លាតុងវិញយល់ថា «មនុស្សកើតមកមានអាកប្បកិរិយាខុសៗ គ្នា ខ្លះល្អ ខ្លះអាក្រក់ ខ្លះ ស្លូត ខ្លះកាចតាមនិស័យពីធម្មជាតិ» ។ ក្នុងតំលៃសីលធម៌ សូក្រាត ចេញមុខប្រឆាំង នឹងពួក សូហ្វីសជាពួកពូកែអួត ដែលចូលចិត្តយកពាក្យសំដីទៅប្រើផ្លូវខុស ហើយធ្វើអាកប្បកិរិយាដូចជា អ្នកចេះដឹងច្រើន។

សូក្រាតជាមនុស្សថ្មី ចំឡែកដែលបានក្លាយជា ទស្សនវិទូគំរូមួយរូប សម្រាប់មនុស្សជំនាន់ ក្រោយ ។ គេតែងនិយាយថា «សូក្រាត ជាមនុស្សនៃក្រុងអាតែន ដែលមានរូបអាក្រក់ ហើយល្អ ជាងគេបំផុត» ៕

# ទស្សនៈរបស់ផ្លាតូ (៤២៧-៣៤៧ មុន គ.ស.)

## ជីវប្រវត្តិសង្ខេបរបស់ផ្លាតូ



ផ្លាតូ កើតក្នុងឆ្នាំ ៤២៧ មុន គ.ស. គឺជាទស្សនវិទូក្រិចបុរាណ ដែលបានរួមចំណែកបង្កើតនូវមូលដ្ឋានសម្រាប់ទស្សនវិជ្ជាលោកខាងលិចជាមួយគ្រូរបស់គាត់ **សូក្រាត** និង

សិស្សរបស់គាត់ **អារីស្តូត** ។ ផ្លាតូ ក៏ជាគណិតវិទូ អ្នកនិពន្ធនៃទស្សនវិជ្ជាបែបសន្ទនា និងជាអ្នកបង្កើតសាលាទស្សនវិជ្ជាជាន់ខ្ពស់អាកាដឺមី (Academi) នៅក្រុង អាតែនដែលជាវិទ្យាស្ថានគរុវិជ្ជាជាន់ខ្ពស់ដំបូងបង្អស់នៅលោកខាងលិច ។ ផ្លាតូគឺជាសិស្សរបស់សូក្រាត និងបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីការត្រិះរិះរបស់សូក្រាត ។ មរណៈភាពរបស់គាត់ក្នុងឆ្នាំ ៣៤៧ មុន គ.ស ៕

## លក្ខណៈទូទៅរបស់ផ្លាតូ

ផ្លាតូ ក៏ជាអ្នកនយោបាយម្នាក់ដែរ ក្នុងចំណោមអ្នកនយោបាយទាំងឡាយ ។ចំណង់ចំណូលចិត្តរបស់គាត់ គឺផ្តោតទៅលើរដ្ឋនយោបាយ និងច្បាប់ ។ ធាតុទាំងនេះ ជាកត្តាជំរុញឲ្យគាត់ចាប់អារម្មណ៍ទៅលើប្រជាជន ចង់ឲ្យប្រជាជនមានភាពប្រសើរសំបូរសប្បាយ និងសុភមង្គល ព្រមទាំងធ្វើឲ្យសង្គមទាំងមូល ស្ថិតក្នុងស្ថេរភាពទាំងផ្នែកសេដ្ឋកិច្ចទាំងផ្នែកនយោបាយ ។ ល ។ ផ្លាតូ ព្យាយាមដោះស្រាយរាល់បញ្ហាទាំងឡាយ ដែលគេតែងតែជួបប្រទះក្នុងរដ្ឋក្នុងសង្គម ក៏ដូចជាក្នុងជីវភាពរស់នៅផងដែរ ដោយប្រើវិធីមួយ គឺបង្កើតរដ្ឋគំរូ ដែលមានមេដឹកនាំប្រកបដោយគំនិតស្នេហាជាតិ មានសុភវិនិច្ឆ័យ ។ រដ្ឋគំរូនោះ លោកផ្លាតូ បានធ្វើការប្រៀបធៀបរវាងទំរង់គ្រប់គ្រងនយោបាយ ដែលមានលក្ខណៈមិនគ្រប់គ្រាន់ជាច្រើន ដូចជាទំរង់សក្តិភូមិ (Timocracy) គណាធិបតេយ្យ (Oligarchy) និងប្រជាធិបតេយ្យ (Democracy) ទំរង់ទាំង ៣ នេះ គាត់ឲ្យឈ្មោះថាជាទំរង់អាក្រក់ គ្មានស្ថេរភាព ហើយទីបំផុតក្លាយទៅជាទុជនាធិបតេយ្យ(Tyranny) ។

អត្ថន័យរដ្ឋគំរូរបស់លោកផ្លាតូ បានបង្ហាញឲ្យឃើញនូវភាពយុត្តិធម៌ ក្នុងការដឹកនាំដោយជ្រើសរើសយកអ្នកទស្សនវិទូដ៏វៃឆ្លាត ពីព្រោះចំណេះដឹងពិតប្រាកដ និងចិត្តសាងកុសលចំពោះអ្នកដទៃ មានតែនៅក្នុងជំពូកមនុស្សប្រភេទនេះទេ ដែលបានធ្វើសម្បទាន ។ តួរអង្គដែលតំណាងឲ្យរដ្ឋគំរូរបស់លោកផ្លាតូ គឺអ្នកធ្វើការក្នុង Polis (ក្រុងក្រិចបុរាណ) ។ នៅក្នុងគំនិតនយោបាយផ្ទាល់របស់ផ្លាតូ ពាក្យសង្គម និងរដ្ឋ គឺរលាយចូលគ្នាក្នុងបូរី ។ផ្លាតូមានជំនឿថា «គ្រប់បុគ្គលទាំងអស់ ពុំមានចំណេះដឹងពិតប្រាដកទេ ហេតុដូច្នេះហើយ បានជាពួកគេយកចិត្តទុកដាក់គោរពតាមបុគ្គលតែមួយអ្នកក្តី ឬរដ្ឋ » ។




វណ្ណៈខ្ពស់បំផុត ដែលកំពុងកាន់អំណាច ពុំត្រូវអនុញ្ញាតឲ្យមាននូវករណីលើកលែង ឬករណីចាំបាច់ឡើយ គឺត្រូវធ្វើការបូជាជីវិតដើម្បីរដ្ឋដើម្បីវឌ្ឍនភាពរបស់រដ្ឋ ។ ពលរដ្ឋទាំងអស់ ត្រូវផ្សារសាច់ឈាមរលាយចូលទៅក្នុងរដ្ឋហើយរដ្ឋ ក៏កើតឡើងដោយសារតែពលរដ្ឋដែរ ។ ដូច្នេះពុំអាចអ្នកណាម្នាក់ ក្នុងរដ្ឋាភិបាលមានសុភមង្គលតែឯកឯងបានទេ ហើយអ្នកដទៃទៀតរស់លើគំនរទុក្ខ និងស្ទឹងទឹកភ្នែក បានន័យថា ពលរដ្ឋទាំងអស់ ក្នុងប្រទេសត្រូវតែមានសុភមង្គលដូចៗ គ្នា ។ នៅក្នុងទ្រឹស្តីនយោបាយរបស់លោកផ្លាតូ គឺបង្ហាញឲ្យឃើញនូវគំនិតផ្តាច់ការទាំងឡាយ ដែលពុំអាចធ្វើការបិទបាំង នៃជំរៅអត្ថន័យរបស់វា ហើយមិនមានការពិបាកយល់ទេ ព្រោះវាជាមូលដ្ឋានសុខមាលភាពរបស់រដ្ឋ ៕

## ទស្សនវិជ្ជារបស់ផ្លាតូ

តាមទស្សនៈរបស់ផ្លាតូថា «ពិភពលោក កើតឡើងដោយធាតុ ២ យ៉ាង គឺពិភពទស្សនៈ និងរូបធាតុ ។ ពិភពទស្សនៈ មិនសំដៅទៅលើរចនាសម្ព័ន្ធគំនិតនោះទេ ប៉ុន្តែជាពិភពសច្ចៈដែលសម្តែងបង្ហាញនូវភាពជាក់ស្តែង ។ ចំណែករូបធាតុនិយមនៅក្នុងដំណើរវិវត្តន៍របស់ខ្លួន គ្មានភាពសច្ចៈទេ» ។ ផ្លាតូបានបង្ហាញថា «គ្មានរូបធាតុណាមួយ មិនប្រែប្រួលបាត់បង់នូវស្ថានភាពរបស់វាទេ គឺមានតែការប្រែប្រួលប៉ុណ្ណោះ ដែលមិនប្រែប្រួល» ។ បានន័យថា គឺមានតែពិភពទស្សនៈទេ ដែលមានភាពសច្ចៈ និងមិនប្រែប្រួល ចំណែកឯរូបធាតុវិញ មានលក្ខណៈស្រពិចស្រពិលមិនមានភាពសច្ចៈ គឺវាមិនឆ្លើយតបទៅ នឹងសភាព

លក្ខណៈខាងក្រៅខ្លួនរបស់វា គ្រប់ពេលវេលានោះទេ ផ្លាតូបានរិះរកទស្សនៈរបស់មេដឹកនាំដ៏ល្បីល្បាញជាងគេ ដែលមាននៅក្នុងស្នាដៃរបស់គាត់ស្ដីអំពី «ពលកម្ម និងពេលវេលា» ដែលត្រូវបានគេទទួលស្គាល់ និងចាត់ទុកថាជាទេវកថា ឬជាសតវត្សមាសដ៏ល្អអាចយកធ្វើជាគំរូបានហើយជាស្នាដៃដែលប្រកាន់ភ្ជាប់នូវរបបនយោបាយល្អប្រសើរ ។ នៅអតីតកាល ប្រវត្តិសាស្ត្រ ធ្វើដំណើរលើផ្លូវដែលមិនត្រូវដើរចេញពីសតវត្សមាសទៅកាន់សតវត្សដែក គឺថារចនាសម្ព័ន្ធរបស់រដ្ឋគំរូ មានតែនៅក្នុងសតវត្សមាសទេ ។តើរដ្ឋគំរូរបស់ផ្លាតូ មានសញ្ញាណយ៉ាងដូចម្ដេច? បើតាមទស្សនៈរបស់ផ្លាតូ ដែលបាននិយាយនៅក្នុងស្នាដៃរដ្ឋសញ្ញាណដ៏សំខាន់របស់រដ្ឋជាគំរូ គឺភាពយុត្តិធម៌ ។ ភាពយុត្តិធម៌បើតាមទស្សនៈរបស់ផ្លាតូគឺស្ថិតនៅត្រង់ថាពលរដ្ឋម្នាក់ ត្រូវតែមានការងារធ្វើ ហើយអាស្រ័យទៅតាមឧបនិស្ស័យរបស់គេ ដូច្នេះភាពយុត្តិធម៌របស់រដ្ឋគឺពលរដ្ឋត្រូវមានការងារធ្វើ ហើយធ្វើសកម្មភាពស្របទៅតាមសមត្ថភាព និងអត្តិភាពរបស់ខ្លួនផ្ទាល់ ។ លោកផ្លាតូបានធ្វើការបែងចែកយ៉ាងច្បាស់នូវឋានានុក្រមស្រទាប់របស់មនុស្ស ក្នុងសង្គមថា ពួកទស្សនៈវិទូដែលដឹកនាំប្រទេស ជាវណ្ណៈជាន់ខ្ពស់ អ្នកយាម និងទាហានមន្ត្រីរាជការ ជាវណ្ណៈកណ្ដាល) អ្នកសិប្បករ និងកសិករ ជាវណ្ណៈក្រោម។ មិនតែប៉ុណ្ណោះ ប្លាតូបានពិនិត្យយ៉ាងហ្មត់ចត់ លើបញ្ហាការសិក្សា និងការអប់រំ ។

ផ្លាតូបានធ្វើការបែងចែកដូច្នេះ «អាស្រ័យលើឧបនិស្ស័យរបស់មនុស្ស គឺភាពវៃឆ្លាត ភាពម៉ឺងម៉ាត់ និងការទទួលខុសត្រូវក្នុងភាពជាអ្នកដឹកនាំ» ។ សម្រាប់លោកផ្លាតូ រចនាសម្ព័ន្ធល្អ គឺនៅកន្លែងណាដែលពលរដ្ឋម្នាក់ៗ ធ្វើការដើម្បីប្រយោជន៍របស់ខ្លួននៅក្នុងទិសដៅអភិវឌ្ឍន៍សង្គម ។ រដ្ឋនិងសង្គមពលរដ្ឋរបស់ផ្លាតូ គឺមានលក្ខណៈតែមួយ។ តាមការពិនិត្យវណ្ណៈទាំងឡាយ ដូចជាមេដឹកនាំ (ក្សត្រ) កងទ័ព (អាមាត្យ) ឈ្មួញ សិប្បករ និងម្ចាស់ដី លោកផ្លាតូ បានបង្ហាញថា «វណ្ណៈដែលមានតួរនាទីសំខាន់ជាងគេក្នុងរដ្ឋ គឺមេដឹកនាំ ក្សត្រ) និងកងទ័ព (អាមាត្យ)។ រីឯឈ្មួញកសិករ និងដែលមានជីវិតផ្សារភ្ជាប់នឹងផលិតផលសម្ភារៈនោះ ពួកគេមិនអាចជៀសផុតពីការអាស្រ័យនូវរដ្ឋនោះទេ ទីបំផុតពួកវណ្ណៈទាំងពីរនេះប្រឹងប្រែងសន្សំទ្រព្យសម្បត្តិ ដែលជាហេតុនាំឲ្យកើតមានឡើងនូវអ្នកមានពេកនិងអ្នកក្រពេក» ។ ដើម្បីរក្សាស្ថានភាពនេះ ផ្លាតូទាមទារឲ្យមានការបង្កើតប្រព័ន្ធអប់រំពិសេសមួយសម្រាប់ក្រុមអ្នកដឹកនាំ និងអ្នកការពារ ។ នៅក្នុងមូលនៃប្រព័ន្ធអប់រំនេះ ត្រូវមានសិល្បៈតូរ្យតន្ត្រី និងអត្តពលកម្មចូលរួមផងដែរ។ តូរ្យតន្ត្រីពង្រឹងដួងប្រលឹងអប់រំឲ្យស្រលាញ់ជាតិមាតុភូមិ ចំណែកឯអត្តពលកម្មពង្រឹងរាង្គកាយឲ្យរឹងមាំរៀបចំ

ពលរដ្ឋដើម្បីរដ្ឋរបស់ខ្លួន ។ តាមទស្សនៈរបស់ផ្លាតូ ការសិក្សាវិទ្យាសាស្រ្តជាការស្វែងរកពិតភពសច្ចភាពហើយមិនភូតភរ ដូចជាលក្ខណៈរូបធាតុទេ ។ បន្ទាប់ពីបានបញ្ចប់នូវមុខវិជ្ជាទាំងអស់នេះ យុវវ័យមានការចេះដឹងនិងប្រកបដោយសីលធម៌នោះ អាចរៀបចំខ្លួនដើម្បីដើរតួរជាមេដឹកនាំ ។ ពេលនេះគេសិក្សាវិភាគអំពីសិល្បៈ និងដឹកនាំជជែកពិភាក្សាបន្ទាប់មកសិក្សាទស្សនវិជ្ជា ដែលជាប្រភពដើមនៃរាល់ប្រព័ន្ធចំណេះដឹង ។ នៅចុងកម្មវិធីសិក្សាពួកគេត្រូវតែងតាំងឱ្យមានមុខងារជាបុគ្គលិករដ្ឋ ប៉ុន្តែមិនទាន់មានមុខងារដឹកនាំរដ្ឋទេ លុះត្រាតែមានវ័យចាប់ពី ៥០ ឆ្នាំឡើងទៅ ស្គាល់នូវទិសដៅនៃជីវិតច្បាស់លាស់ ។ ចេះធ្វើការអង្កេតពិនិត្យទទួលយកនូវទស្សនៈដែលជឿនលឿន និងមានការសម្របសម្រួលទទួលយកបទពិសោធន៍ជាច្រើនអំពីរដ្ឋ ។ គេនៅពេលនោះគេមានលក្ខណសម្បត្តិពេញលេញ ក្លាយជាមេដឹកនាំរដ្ឋពិតប្រាកដ ។ បើតាមទស្សនៈរបស់ផ្លាតូ ទិសដៅរបស់រដ្ឋដែលផ្លាតូ គិតថាជារដ្ឋគំរូ គឺត្រូវជួយផ្គត់ផ្គង់អតិបរមាដល់ដល់កង្វះខាតក្នុងជីវិតប្រជាពលរដ្ឋ ទាំងសម្ភារៈ ទាំងស្មារតី ។ ស្ថានភាពនៃជីវិតនេះហើយ ដែលគេបានគិតទទួលយកនៅក្នុងសម័យបុរេក្រិច និងរូម ។ ដូច្នេះរដ្ឋគំរូរបស់ផ្លាតូត្រូវតែអាស្រ័យនឹងការបែងចែកជាក្រុម ដែលប្រកបដោយគុណធម៌ទាំងឡាយ បួនយ៉ាងគឺ

-ចំណេះដឹងជ្រៅជ្រះ

-សេចក្តីក្លាហាន

-វិចារណញ្ញាណ

-យុត្តិធម៌ ។

ចំណេះដឹងជ្រៅជ្រះ ក្នុងនាមជាអ្នកបំពេញតួនាទី ជាអ្នកដឹកនាំរដ្ឋ ។ សេចក្តីក្លាហាន ជាគុណសម្បត្តិរបស់ទាហានមានតួនាទី ជាអ្នកការពារ ។ ទីបី និងទីបួន គឺវិចារណញ្ញាណ និងយុត្តិធម៌ជាគុណធម៌ដែលមានគ្រប់ពលរដ្ឋទាំងអស់នៅក្នុងរដ្ឋគំរូ ។

ទន្ទឹមនឹងនេះ គួរតែធ្វើការកត់សំគាល់ផងដែរ នៅក្នុងសំណេរស្នាដៃរដ្ឋគំរូរបស់ផ្លាតូ គេសង្កេតឃើញមានការផ្សព្វផ្សាយនូវទេវកថាបុរេក្រិច ស្តីអំពីមនុស្សប្រាំជំនាន់ ដែលបានផ្លាស់ប្តូរដែលស្ថិតនៅក្នុងកំណាព្យរបស់កវី Gesioda ថា «ពលកម្ម និងពេលវេលា» ។ ទីមួយ ឬសតវត្សមាស គឺជាជំនាន់មនុស្សដែលទទួលបាននូវអ្វីជាគំរូ ។នៅក្នុងជំនាន់នោះគេមានគុណធម៌គ្រប់បែបយ៉ាងទាំងអស់ ហើយឋិតក្រោមការដឹកនាំរបបរាជានិយម។ ជំនាន់ក្រោយមក បានចប់ផ្តើមឃ្លាតចេញ ពីតំណាក់កាលសតវត្សមាស ។ កើតឡើង នូវតំណាក់កាល ដែលបានកាត់ផ្តាច់នូវគុណធម៌ទាំអស់ ។ គឺនៅក្នុងទេវកថានេះ ត្រូវនឹង

ស្នាដៃរបស់ផ្លាតូ ដែលនិយាយអំពីរបបនយោបាយ និងរចនាសម្ព័ន្ធដឹកនាំ ដែលរបបរាជានិយម និងអភិជនាធិបតេយ្យ បានកាត់បង់នូវស្ថានសួគ៌របស់ខ្លួន រីឯរចនាសម្ព័ន្ធនយោបាយសង្គមបួនទៀត កំណត់ភាពទន់ខ្សោយរបស់ប្រជាពលរដ្ឋ ក្នុងការប្រឹងប្រែងដើម្បីគុណធម៌ និងសីលធម៌នៅក្នុងជីវិត ។ ទស្សនៈរបស់ផ្លាតូ មានគោលការណ៍ នៅក្នុងអតីតកាល ដែលអ្នកទស្សនវិទូ មើលឃើញគំរូនយោបាយរបស់ខ្លួន ៕

## ការបែងចែករបបអ្នកដឹកនាំរបស់ផ្លាតូ

ផ្លាតូបានបែងចែកនូវទ្រង់ទ្រាយដឹកនាំដូចតទៅ៖

-រាជាធិបតេយ្យ((Monarchy)

-អភិជនាធិបតេយ្យ((Aristocracy)

-សក្តិភូមិ (Timocracy)

-គណាធិបតេយ្យ((Oligrachy )

-ប្រជាធិបតេយ្យ( (Democracy )

-ទុជនាធិបតេយ្យ( (Tyranny )

ផ្លាតូ បានបែងចែកដូច្នេះ ភាពត្រឹមត្រូវជាគូ នឹងវិចារណញ្ញាណ បន្ទាប់មកគុណធម៌ និងភាពខ្វះខាត (អគុណធម៌)បន្ទាប់មកសុភមង្គល និងអពមង្គល ។ ផ្លាតូ បានចាត់ទុករបបរាជាធិបតេយ្យ និងអភិជនាធិបតេយ្យជារបបនយោបាយដឹកនាំល្អប្រសើរជាងគេ ដែលមានយុត្តិធម៌ ជាកន្លែងដែលមានមេដឹកនាំទាំងអស់ ព្រួយបារម្ភអំពីភាពរុងរឿងរបស់រដ្ឋដែលជាលក្ខណៈត្រឹមត្រូវ និងជាគំរូ ៕

ទ្រង់ទ្រាយរចនាសម្ព័ន្ធដឹកនាំ ៤ ទៀត គឺសក្តិភូមិ (Timocracy) គណាធិបតេយ្យ (Oligrachy) ប្រជាធិបតេយ្យ (Democracy) និងទុជនាធិបតេយ្យ (Tyranny) បានឃ្លាតចាកពីរដ្ឋគំរូ ។ និយាយឲ្យខ្លីទៅ ទ្រង់ទ្រាយដឹកនាំរដ្ឋទាំង ៤ ខាងលើ គឺជាការដឹកនាំមួយដែលមេដឹកនាំមានការស្រលាញ់អំណាចហួស ។ របបអភិជនាធិបតេយ្យ (Aristocracy) គឺជាការដឹកនាំមួយដ៏ល្អប្រសើរ មានទំនុកទុកចិត្តពីប្រជាជន ។ អំណាចរបស់រដ្ឋនៅក្នុងដៃអ្នកដែលប្រសើរជាង ដែលបានផ្តល់ឲ្យដោយសុទ្ធចិត្តពីប្រជាជន ។ អំណាចរបស់រដ្ឋ ដឹកនាំប្រកបទៅដោយគុណធម៌ និងវ័យឆ្លាត ។ នៅលើគោលការណ៍ និងទ្រង់ទ្រាយនៃរចនាសម្ព័ន្ធដឹកនាំបែបនេះ គឺមានសមភាពតាំងពីកំនើតម្លេះ ។ផ្លាតូបានអះអាងថា «សមភាពពីកំនើត បង្ខំឲ្យមានច្បាប់សមភាពសម្រាប់ទាំងអស់គ្នា ដែលបានសរសេរទុកនៅក្នុងច្បាប់

និងជាកាតព្វកិច្ចសម្រាប់ទាំងអស់គ្នា ធ្វើសកម្មភាពចំពោះគ្នាទៅវិញទៅមក ក្នុងលក្ខណ្ឌដ៏ប្រកបមួយ គឺពោរពេញទៅដោយកម្លាំងកិត្យានុភាព វីរភាព និងវិចរណញ្ញាណ» ។

ប៉ុន្តែទស្សនៈ របស់ផ្លាតូ ចំពោះតួនាទីរបស់មេដឹកនាំរដ្ឋគំរូ គឺចំពោះអ្នកណាមួយដែលស្ម័គ្រចិត្ត មិនចង់ធ្វើជាអ្នកដឹកនាំទាល់តែសោះ តែចង់ធ្វើការកែកំហុសរបស់អ្នកដទៃ ។ អ្នកដែលមិនមែនជាអ្នកដឹកនាំគំរូ គឺសំដៅទៅលើអ្នកណាដែលស្រលាញ់ខ្លួនឯងស្រលាញ់លុយ និងស្រលាញ់បុណ្យសក្តិ ។ ពីព្រោះអ្នកដឹកនាំណាមួយដែលមានលក្ខណៈដឹកនាំល្អសុទ្ធសាធនោះ មិនមែនធ្វើសកម្មភាពដើម្បីតែខ្លួនឯងនោះទេ គឺដើម្បីភាពសំបូរសប្បាយរុងរឿងជូនអ្នកដែលនៅក្រោមបង្គាប់របស់ខ្លួន ។ ផ្លាតូ បានបង្ហាញថាបើនៅក្នុងរដ្ឋសុទ្ធតែមនុស្សល្អនោះលទ្ធភាពក្នុងការកាន់អំណាចនឹងមានច្រើន ។ ប៉ុន្តែមេដឹកនាំពិតប្រាកដ ត្រូវមានគុណសម្បត្តិល្អ សម្រាប់ខ្លួនឯងផងនិងសម្រាប់អ្នកនៅក្រោមបញ្ជាផង ។ ហេតុដូច្នេះ អ្នកដែលដឹកនាំល្អបំផុត មានលក្ខណៈវិសេសវិសាលឆ្លាតវៃជាងគេមានសមត្ថភាពខ្ពស់ជាងគេមានវង្សត្រកូលប្រកបទៅដោយគុណធម៌ ហើយលើសពីនេះទៅទៀត គឺត្រូវគិតគូរដល់អ្នកដទៃនិងរដ្ឋ ។ មានន័យថាការងាររួម គឺជាការងាររបស់ខ្លួនផ្ទាល់ជ័យជំនះទៅលើការងាររួមក៏ជាជ័យជំនះរបស់ខ្លួនឯងដែរ ។ ត្រូវតែជ្រើសរើសមេដឹកនាំដែលមានគុណសម្បត្តិដូច្នេះ ។ ព្រោះទិសដៅនៅក្នុងជីវិតគឺដើម្បីវឌ្ឍនភាពរដ្ឋ ។ គុណសម្បត្តិដ៏សំខាន់ សម្រាប់មេដឹកនាំតាមទស្សនៈរបស់ផ្លាតូ គឺសីលធម៌ ភាពនឹងហ្ន៎ និងមិនឆេវឆាវ ។ ផ្លាតូ បានចង្អុលបង្ហាញគុណសម្បត្តិមេដឹកនាំ ដើម្បីអាចបង្កឱកាសឲ្យអ្នកធ្វើការជុំវិញបណ្តុំទៅដោយមនុស្សស្ម័គ្រចិត្ត ធ្វើការដោយសុទ្ធចិត្ត ហើយសុទ្ធតែជាមនុស្ស មានគុណសម្បត្តិល្អប្រពៃហើយក៏ជាសម្ព័ន្ធមិត្តដ៏ល្អប្រសើរ របស់ប្រជាពលរដ្ឋផងដែរ ។ ទាំងអស់នេះ ត្រូវដឹកនាំដោយវិចារណញ្ញាណ ។ភាពឆ្លាតវៃ គឺជាផ្លូវចង្អុលបង្ហាញគំនិតដ៏ល្អប្រសើរ ។ អពមង្គល នឹងកើតឡើងមិនចេះចប់ ទាំងចំពោះរដ្ឋទាំងចំពោះពលរដ្ឋ ក្នុងខណៈណាដែលអ្នកដឹកនាំមិនមែនជាទស្សនៈវិទូ ពីព្រោះទស្សនៈវិទូនេះហើយ គឺជាផលវិជ្ជមាននៃសច្ចធម៌ និងអត្ថិភាពហើយក្រៅអំពីទស្សនៈវិទូនេះ គឺមិនដែលនាំមកនូវសមិទ្ធិផលអ្វីដ៏គាប់ប្រសើរធំធេងទេសម្រាប់បច្ចេកបុគ្គល (ខ្លួនឯង) ក៏ដូចជាសម្រាប់រដ្ឋ ឬពលរដ្ឋ ។ លក្ខណៈធម្មជាតិរបស់ទស្សនៈវិទូ គឺជាលទ្ធភាពល្អលើកកម្ពស់គំរូទស្សនៈ និងភាពក្លាហាន ។ លក្ខណៈធម្មជាតិរបស់ទស្សនៈវិទូ ជាបងប្អូន នឹងការលើកកម្ពស់នូវភាពរុងរឿង ។ មានតែនៅក្នុងរដ្ឋប្រកបដោយយុត្តិធម៌ទេ ដែលជាកន្លែងអភិជន នឹងដឹកនាំពោរពេញទៅដោយភាពសម្បូរសប្បាយ ប៉ុន្តែមិនមែនសម្បូរមាសប្រាក់ទេ គឺសម្បូរសប្បាយដោយសុភ

មង្គលប្រកបដោយសីលធម៌និងវិចារណញ្ញាណ នៅក្នុងជីវិត ។ ច្បាប់ បង្ខំឲ្យកំណត់ទិសមិនមែនដើម្បីភាពសម្បូរសប្បាយតែម្នាក់ឯងទេ គឺដើម្បីរដ្ឋទាំងមូល ។ នៅក្នុងរដ្ឋបច្ចុប្បន្ន ត្រូវតែមាននូវភាពយុត្តិធម៌ ព្រោះអំណាចរបស់រាជា អ្នកដឹកនាំ តាមទស្សនៈរបស់ផ្លាតូ គឺឆ្លើយតបទៅនឹងគុណធម៌ពេញលេញ ។ បើសិនជាមេដឹកនាំមួយចំនួននោះគឺជាអភិជនពិត ប៉ុន្តែការដឹកនាំរបស់ពួកនោះ ពុំសូវគ្រប់លក្ខណៈគុណធម៌ ដែលចង់បានទេ នោះឯង គឺជាមូលហេតុឲ្យកើតការស្រលាញ់អំណាចហួស ដូច្នេះ ការដឹកនាំបែបនោះគឺជាបែបសក្តិភូមិ ៕

**លក្ខណៈរបបសក្តិភូមិ** ((Timocracy)

សម្រាប់របបសក្តិភូមិ គឺមានលក្ខណៈ ជាគូប្រកួតប្រជែង និងការប្រឹងប្រែងដើម្បីអំណាច នៅក្នុងរចនាសម្ព័ន្ធរដ្ឋបែបនេះ គេមិនចង់ដាក់មនុស្សវ័យឆ្លាត នៅក្នុងតួនាទីទេ គឺគេមិនឲ្យតំលៃ ចំពោះមនុស្សមានគុណធម៌ និងភក្តីទេ ប៉ុន្តែឲ្យតំលៃចំពោះមនុស្ស ដែលមានលក្ខណៈធម្មជាតិកាចសាហាវ មានកំណើតមកសម្រាប់ធ្វើសឹកសង្គ្រាម មានការអប់រំឲ្យធ្វើអំពើហឹង្សា ហើយមិនមែនឈរលើគោលការណ៍ ជឿជាក់លើខ្លួនឯងនោះទេ ។ មនុស្សនៅក្នុងសក្តិភូមិមានលក្ខណៈកាចសាហាវ និងមានការចេះដឹងទាប ប៉ុន្តែគេស្តាប់មេដឹកនាំអំណាច ដោយឥតលក្ខ័ន្ត ។ ទ្រង់ទ្រាយដឹកនាំនេះ (សក្តិភូមិ) មានលក្ខណៈប្រហាក់ប្រហែល នឹងលក្ខណៈអភិជន ។ តើទ្រង់ទ្រាយដឹកនាំទាំងពីរនេះ មានលក្ខណៈខុសគ្នាយ៉ាងណា? ដូចម្តេច ដែលហៅថាសក្តិភូមិ? ដើម្បីដោះស្រាយបញ្ហាឲ្យបានទូលំទូលាយត្រូវយល់ថា ហេតុដូចម្តេចត្រូវបាត់បង់រចនាសម្ព័ន្ធរដ្ឋគំរូ? មូលហេតុនៃការបាត់បង់រចនាសម្ព័ន្ធគំរូផ្លាតូ គិតថា មកពីមិនអាចថែរក្សា និងបន្តនូវគុណសម្បត្តិ នៃសីលធម៌ដ៏ខ្ពង់ខ្ពស់ពីជំនាន់មួយទៅជំនាន់មួយ ហេតុដូច្នេះហើយ បានជាកើតឡើងលើលោកនេះ នូវសីលធម៌មួយ ដែលមានគុណធម៌តិចជាង ហើយមនុស្សដែលមានសីលធម៌ច្រើនក៏កាន់តែតិចមនុស្សដែលមានសីលធម៌តិចជាងមុនកាន់តែកើនឡើង ពួកគេមានទិសដៅប្រឹងប្រែងដើម្បីក្លាយជាអ្នកមាន ។ ក្នុងលក្ខណៈនេះហើយ ដែលធ្វើឲ្យខូចបង់នូវរចនាសម្ព័ន្ធរបបអភិជន ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ផ្លាតូ ពុំបានអះអាងថា ទ្រព្យសម្បត្តិជាប្រភពនៃសភាវៈអាក្រក់នោះទេ ។ សម្រាប់ផ្លាតូ ការប្រឹងប្រែងដើម្បីទ្រព្យសម្បត្តិ គឺជាការសន្សំសម្ភារៈដែលនៅក្នុងទស្សនៈវិជ្ជារបស់លោកបានកំណត់ថា ជាកាយវិការមួយនាំឲ្យទស្សនៈសច្ចធម៌ ប្រែក្លាយជាស្រអាប់ស្រពិចស្រពិល ។ ក្រៅពីនេះ គឺភាពមាន និងក្ររបស់ប្រជាពលរដ្ឋនាំឲ្យមានការខូចខាតនូវទំនាក់ទំនងនយោបាយធម្មតានៅក្នុងសង្គម ។

នៅលើគោលការណ៍នេះ បើនិយាយពីរដ្ឋគំរូផ្លាតូ បានគិតថា «ទ្រព្យសម្បត្តិប្រពន្ធនិងកូន របស់ពីរក្រុមដ៏សំខាន់ គឺអ្នកដឹកនាំ និងអ្នកការពារ ត្រូវតែស្ថិតនៅជាកម្មសិទ្ធិរួម» ។នៅក្នុងខណៈណាដែលធ្វើឲ្យខូចនូវលក្ខណៈគោលការណ៍នេះ ទោះរចនាសម្ព័ន្ធអភិជនក៏ដោយ វានឹងបាត់បង់នូវស្ថានភាពពិតរបស់ខ្លួនហើយទន្ទឹមនឹងនេះរចនាសម្ព័ន្ធរដ្ឋគំរូក៏បាត់បង់ដែរ ។ ការប្រឹងប្រែងដើម្បីទទួលបាននូវស្ថានភាពពត៌មានអំពីសំភារៈឬរូបធាតុនេះ ដែលធ្វើឲ្យមនុស្សកាន់តែការជឿងឆ្ងល់ថា ហេតុអ្វីបានជាស្ថានភាពពិតរបស់រូបធាតុ មិនស៊ីគ្នានិងពិភពគំនិត ។ ទន្ទឹមនឹងនេះ ពលរដ្ឋដែលមានលក្ខណៈវិសេសជាងគេពេលនេះ ជាជោគជ័យមួយមិនគ្រប់គ្រាន់ទេគេប្រឹងប្រែងថែមទៀត ដើម្បីពង្រឹង និងពង្រីកតួនាទីរបស់គេ នៅក្នុងសង្គម ។ ក្នុងខណៈនេះ គឺមានតែទ្រព្យសម្បត្តិទេ ដែលគេត្រូវការ ហេតុដូច្នេះហើយ នៅក្នុងសង្គម នឹងនាំឲ្យមានការលើកកម្ពស់ទ្រព្យសម្បត្តិពីលើសីលធម៌ ។ ដូច្នេះហើយ ផ្លាតូ បានបង្ហាញថា «សេចក្តីស្រេកឃ្លានអំណាច នៅក្នុងរបបសក្តិភូមិ ធ្វើឲ្យខូចខាតប្រព័ន្ធគ្រប់គ្រងអំណាចដោយខ្លួនឯងផ្ទាល់តែម្តង» ៕

**លក្ខណៈរបបគណាធិបតេយ្យ (Oligarchy)**

បន្ទាប់ពីរបបសក្តិភូមិ ផ្លាតូ បានហៅរបបថ្មីមួយទៀត គឺរបបគណាធិបតេយ្យ (Oligarchy) ដែលកើតចេញអំពីសក្តិភូមិ (Timocracy) នៅក្នុងលទ្ធផលនៃការដឹកនាំនៅក្នុងសង្គម ។ នៅក្នុងរបបគណាធិបតេយ្យ (Oligarchy) ចូលរួមក្នុងការដឹកនាំប្រទេសមានតែពួកអ្នកមានទ្រព្យសម្បត្តិខ្ពង់ខ្ពស់ រីឯពួកក្រីក្របានកាត់ផ្តាច់ស្រលះ ។ បើសិនជានៅក្នុងរបបសក្តិភូមិ (Timocracy) សារៈសំខាន់មានតែកេរ្តិ៍ឈ្មោះនោះ នៅក្នុងរបបគណាធិបតេយ្យ (Oligarchy) ទិសដៅសំខាន់គឺទ្រព្យសម្បត្តិបើសិនជាប្រៀបធៀបរបបគណាធិបតេយ្យ (Oligarchy) ទៅនឹងរបបសក្តិភូមិ (Tomocracy) គឺទី ១ អាក្រក់ជាងទី ២ ទៅទៀត ។ ការប្រមូលសន្សំមាសរបស់មនុស្សបានធ្វើឲ្យខូចខាតដល់ប្រព័ន្ធសក្តិភូមិ (Timocracy) ជាបឋមពួកគេបានបោះបង់នូវប្រព័ន្ធដែលគេកំពុងប្រើប្រាស់ហើយដើម្បីបំពេញនូវទិសដៅនេះ គេត្រូវបង្កើតច្បាប់ ដែលគិតគូរតិចតួចណាស់ជាមួយនឹងមនុស្ស ។នៅពេលណាដែលពួកគេឲ្យតំលៃមធ្យោបាយគាបសង្កត់កាន់តែខ្លាំងឡើងនោះ គេនឹងឲ្យគុណធម៌កាន់តែតិចដែរ ។ ផ្លាតូ បានបង្ហាញថា ដោយនៅក្នុងរដ្ឋ គេឲ្យតំលៃទៅលើភាពមានស្តុកស្តម្ភទ្រព្យសម្បត្តិ មានន័យថា គេនឹងមានការចុះថយចំពោះតំលៃទៅលើគុណធម៌ដែរ ។ ការឲ្យតំលៃទៅលើទ្រព្យសម្បត្តិកាន់តែកើនឡើង ការលើកកម្ពស់អ្នកមាន នាំឲ្យមានការតែងតាំងពួកនេះ នៅក្នុងម៉ាស៊ីនដឹកនាំនៅពេលនោះ អ្នកក្រពុំមានលទ្ធភាពចូលកាន់តំណែងបាន

ឡើយ ។ ដូច្នេះ ផ្លាតូ បានបង្ហាញថា ការកំណត់ស្ថានភាពទ្រព្យសម្បត្តិ បានក្លាយជាច្បាប់ និងឋានានុក្រម នៃរបបគណាធិបតេយ្យ (Oligarchy) ។ យ៉ាងណាមិញ នៅពេលណា របបគណាធិបតេយ្យ (Oligarchy) កាន់តែរឹងមាំនោះ ការឲ្យតំលៃទៅលើទ្រព្យសម្បត្តិ ក៏កាន់តែខ្លាំងដែរ ។ ដូច្នេះយើងឃើញយ៉ាងច្បាស់ថារបបនេះ អាចថែរក្សាគង់វង្សបានមានតែប្រើមធ្យោបាយហិង្សាទេ ។ ផ្លាតូ បានបង្ហាញថារបបគណាធិបតេយ្យ (Oligarchy) នឹងត្រូវបែកបាក់ជារដ្ឋពីរ គឺរដ្ឋសម្រាប់អ្នកមាន និងរដ្ឋសម្រាប់អ្នកក្រ ។ រដ្ឋទាំងពីរប្រឈមមុខនឹងគ្នាជានិរន្តន៍ ។ ឧក្រិដ្ឋកម្ម នឹងកើតមានឡើងជាញឹកញាប់ នៅក្នុងរបបនេះ ដោយសារតែគំនិតឆ្គួតលីលា ។ ភាពកំណាញ់ និងភាពកេងចំណេញ បានក្លាយជា គុណសម្បត្តិមួយសម្រាប់មនុស្ស ហើយប្រសិនបើមនុស្សប្រភេទនេះ មានទីតាំងរបស់ខ្លួន ក្នុងរបបសក្តិភូមិ សេចក្តីស្នេហា នឹងយសស័ក្តិ នឹងក្លាយជាសេចក្តីស្នេហាមាសប្រាក់ ៕

**លក្ខណៈរបបប្រជាធិបតេយ្យ** (Democracy)

បន្តទៅនេះ ជារចនាសម្ព័ន្ធ ឬរបបនយោបាយ ដឹកនាំរដ្ឋតាមទស្សនៈរបស់ផ្លាតូថា របបប្រជាធិបតេយ្យ ជារបបកើតចេញអំពីប្រព័ន្ធគណាធិបតេយ្យ ។ លទ្ធិប្រជាធិបតេយ្យ បានកើតឡើងនៅពេលណា ដែលអ្នកក្របានទទួលជ័យជំនះ នៅពេលនោះ ពួកសត្រូវរបស់គេមួយចំនួនត្រូវបានសម្លាប់ហើយមួយចំនួនទៀត ត្រូវបានបណ្តេញចេញ រីឯអ្នកដែលនៅសល់បានបន្តការរស់នៅក្នុងគោលការណ៍សមភាព ក្នុងឋានៈជាពលរដ្ឋ ។ នៅក្នុងរដ្ឋដែលមានសិទ្ធិសេរីភាពពេលលេញឥតលាក់លៀម និងមានសទ្ធិធ្វើអ្វីដែលខ្លួនចង់ធ្វើមិនចាំបាច់ត្រូវឱនលំទោនចំពោះអ្នកណានោះទេ បើខ្លួនមិនចង់ធ្វើ (ព្រោះជាសទ្ធិរបស់ខ្លួន) ។ ដូច្នេះ មើលទៅហាក់ដូចជា របបនយោបាយមួយនេះ ល្អប្រសើរបំផុតជាងគេ ។ ប៉ុន្តែ នៅក្នុងរបបនេះ ពុំមានអ្នកណាមួយមានទួនាទីត្រូវតែដឹកនាំនោះទេ ។ នៅក្នុងរបបប្រជាធិបតេយ្យ មនុស្សមានអំណាច កេរ្តិ៍ឈ្មោះ យសស័ក្តិ គឺអាស្រ័យពួកមហាជនមើលឃើញ ជ្រើសរើសយក ។ យ៉ាងណាមិញ នៅក្នុងរបបប្រជាធិបតេយ្យ ក៏មិនមែនអាស្រ័យទៅលើបុគ្គលណា ដែលចូលរួមក្នុងសកម្មភាពដឹកនាំរដ្ឋ ។ ដូច្នេះ តាមទស្សនៈរបស់ផ្លាតូ នៅក្នុងរបបប្រជាធិបតេយ្យ នឹងកើតឡើងនូវភាពអួតអាង ការឲ្យមាន សេរីភាពហួសហេតុ ការមិនមានទំទួលខុសត្រូវ ចំពោះពាក្យសម្តី និងភាពឥតខ្មាសទាំងនេះ គឺជាវីរភាពរបស់គេ ។ នៅក្នុងរដ្ឋប្រជាធិបតេយ្យ អ្នកឮសូរតែពាក្យសរសើរ ដោយឥតព្រំដែនតែអំពីសទ្ធិសេរីភាពប៉ុណ្ណោះ ។ នៅពេលដែលអ្នកមិនស្តាប់បង្គាប់ បះបោរឡើងធម្មតាពេលនោះ ឪពុកតែងតែមានទំលាប់គំរាមគំហែងកូន របស់ខ្លួនបើសិនជាត្រូវិញ គឺ

តែងតែប្រតិកម្មចំពោះកូនសិស្សរបស់ខ្លួន ។ នៅក្នុងជួរប្រជាជន នៃរបបប្រជាធិបតេយ្យ និងកើតឡើងនូវភាពមិនសុខ មានអារម្មណ៍ហាក់ដូចជាចង្អៀតចង្អល់រហូតដូចជាមានអ្វីមករារាំងគេជាប់ជានិច្ច ទីបំផុតពួកគេលែងគិតអំពីច្បាប់សំខាន់ គេចង់បានមិនត្រូវឲ្យមានអំណាចណាមួយ មកគ្របសង្កត់លើគេឡើយ។ ក្នុងលក្ខណៈនេះហើយ ដែលនាំឲ្យកើតមាននូវរបបផ្តាច់ការ ។ដូច្នេះ ចេញអំពីសេរីភាព នឹងកើតឡើង នូវរបបទាសភាពដ៏ព្រៃផ្សៃ និងកាចសាហាវបំផុត ៕

**លក្ខណៈរបបទុជនាធិបតេយ្យ** (Tyranny)

ទុជនាធិបតេយ្យ គឺជារបបផ្តាច់ការ ដែលមានទ្រង់ទ្រាយរចនាសម្ព័ន្ធរឹងមាំ ហើយក៏ជារបបកាចសាហាវ ។ ពេលដែលពួកមហាជន ឱនលំទោនស្តាប់បង្គប់តាមនៅពេលនោះ មេដឹកនាំ នឹងក្លាយជាមេដឹកនាំផ្តាច់ការហើយមេដឹកនាំ ចាប់អារម្មណ៍ទៅនឹងសេចក្តីសម្រេចចិត្តរបស់តុលាការ ដែមានលក្ខណៈអយុត្តិធម៌កាត់ផ្តាច់ពីមនុស្ស ដោយប្រើមធ្យោបាយដាក់ទណ្ឌកម្មយ៉ាងកាចសហាវ នៅពេលនេះ គេបានឈរនៅលើផ្លូវ នៃមេដឹកនាំរដ្ឋដែលមិនមែនជាតំណាងរបស់ប្រជាជនទេ គឺជាមេដឹកនាំផ្តាច់ការ ។ កម្មវិធីមួយរបស់មេដឹកនាំផ្តាច់ការ គឺការទាក់អារម្មណ៍ របស់ប្រជាជន ដើម្បីធ្វើសង្គ្រាមដើម្បីឲ្យប្រជាជនមានអារម្មណ៍ត្រូវគ្នា ជាមួយមេដឹកនាំជានិច្ច ។ ដើម្បី ការពារអំណាច មេដឹកនាំផ្តាច់ការ ត្រូវការតាមដានសកម្មភាពអ្នកណា ដែលក្លាហាន មានទឹកចិត្ត ទូលំទូលាយប្រកបដោយវិចារណញ្ញាណ និងប្រាជ្ញាឈ្លាសវៃ ។ ភាពរឹងមាំរបស់អំណាចផ្តាច់ការ គឺធ្វើយ៉ាងណាដើម្បីបោលសំអាតពួកនេះចេញ ពីជួររដ្ឋាភិបាល ។ មធ្យោបាយ របស់មេដឹកនាំផ្តាច់ការ នៅពេលដែលគេធ្វើអំពើកាចសាហាវ ទៅលើប្រជាជន កាន់តែខ្លាំងនោះ គេកាន់តែត្រូវការអ្នកការពារខ្លួនរបស់គេកាន់តែច្រើនថែមទៀត ។ ដូច្នេះ ប្រជាជនដែលមានសេរីភាព ត្រូវធ្លាក់ចូលទៅក្នុងស្ថានភាព នូវអំណាចផ្តាច់ការសេរី របស់ពួកគេត្រូវបាត់បង់ទៅក្នុងរបបផ្តាច់ការ សេរីភាព ត្រូវបានប្រែក្លាយទៅជា ទាសភាពយ៉ាងធ្ងន់ធ្ងរ និងជួរចត់ជាទីបំផុត ក្នុងភាពជាទាសករ ។បើនិយាយពីគុណសម្បត្តិរបស់មេដឹកនាំផ្តាច់ការខ្សោយបំផុត ផ្លាតូ បានបង្ហាញថា ទោះបីគេមានទំនាក់ទំនង ជាមួយអ្នកណាក៏ដោយ ក៏គេតែងតែចង់ទាមទារឲ្យអ្នកនោះ ក្លាយជាទាសកររបស់គេ ។ មេដឹកនាំផ្តាច់ការប្រៀបដូចជាអំណាចគ្មានច្បាប់ របស់មនុស្សម្នាក់ សម្រាប់ប្រជាជនទាំងអស់ នៅក្នុងសង្គមហើយផលប្រយោជន៏របស់ពួកគេ បានកំណត់ខ្ពស់ជាងផលប្រយោជន៏ របស់ប្រជាពលរដ្ឋ

ទាំងអស់ ។ ផ្លាតូ បានបង្ហាញទៀតថា «របបផ្តាច់ការ គឺជារបប កាចសាហាវជាទីបំផុត ពីព្រោះ៖



*ផ្លាតូ(ខាងឆ្វេង) និងអារីស្តូត(ខាងស្តាំ)*

**ទី១** ប្រជាពលរដ្ឋ នៅក្នុងរបបនេះ មិនមែនចាប់ផ្តើមគោរពឱនលំទោន ចំពោះមនោគមន៍វិជ្ជានោះទេ ចំពោះមនុស្សម្នាក់។

**ទី២** ចំណុចសំខាន់ សម្រាប់រដ្ឋ ត្រូវអាស្រ័យ នឹងមនោគមន៍វិជ្ជា របស់ខ្លួន ។ ផលប្រយោជន៍រដ្ឋ ត្រូវតែមានតំលៃ ខ្ពស់ជាងផលប្រយោជន៍ របស់បុគ្គល ឬផលប្រយោជន៍ពលរដ្ឋក្នុងសង្គម ។ មេអំណាចផ្តាច់ការ និងផលប្រយោជន៍ឯកជន របស់ខ្លួនតែងតែត្រូវបានកំណត់ថា ជាផលប្រយោជន៍ របស់ប្រជាជនទូទៅ ហើយគោលបំណង របស់រដ្ឋបានត្រូវគេយកមកប្រើជាគោលបំណង របស់ប្រជាជន» ៕

# ទស្សនៈរបស់អារីស្តូត (៣៨៤-៣២២ មុន គ.ស.)

# ជីវប្រវត្តិរបស់អារីស្តូត



អារីស្តូត (Aristotle) ជាទស្សនវិទូក្រិច (៣៨៤-៣២២) មុនគ្រឹះសករាជ ។ ចំពោះទស្សនវិជ្ជា លោកក៏បានចាប់អារម្មណ៏ផងដែរ ទៅលើបញ្ហានយោបាយ ។ លោកបានពោលថា «វិទ្យាសាស្រ្តនយោបាយ គឺជាកិច្ចការរបស់រដ្ឋឬសង្គម» ។ តាមគំនិតរបស់អារីស្តូត (Aristotle) រដ្ឋគឺជាសង្គម ។ ហើយរដ្ឋ កើតឡើងដោយសារតែពលរដ្ឋរួមផ្តុំគ្នាជាច្រើន ។

តាមគំនិតរបស់អារីស្តូត (Aristotle) ថា «មនុស្សលោក គឺជាសត្វចេះធ្វើនយោបាយ ពីធម្មជាតិមក ដែលជាលក្ខណៈវិសេសរបស់មនុស្ស មានលក្ខណៈវិសេសមួយទៀត គឺមនុស្សព្យាយាម រស់នៅក្នុងសង្គមរួមទាំងអស់គ្នា ពោលគឺរស់នៅក្នុងរដ្ឋតែមួយ» ។ តាមទស្សនៈ របស់អារីស្តូត (Aristotle) ថា «រដ្ឋ កកើតឡើងដោយសារតែហេតុផលចាំបាច់មួយ គឺធ្វើយ៉ាងណាស់ ឲ្យជីវិតរស់នៅរបស់ពលរដ្ឋ មានភាពប្រសើរជាងមុន ។ ហើយមានតែនៅមជ្ឈមណ្ឌលខាងក្នុងរដ្ឋទេ ដែលបង្កលក្ខខណ្ឌល្អៗ ឲ្យមនុស្សរស់នៅ

ក្នុងភាពសុខដមរម្យនា និងសុភមង្គល ពីព្រោះភាពយុត្តិធម៌ និងសិទ្ធិដែលបានបម្រើផលប្រយោជន៍ ឲ្យប្រជាពលរដ្ឋគ្រប់រូប ដែលនៅក្នុងរដ្ឋប៉ុណ្ណោះ» ។

លោកអារីស្តូត (Aristotle) ជាសិស្សម្នាក់ ក្នុងចំណោមសិស្សជាច្រើនរបស់ ផ្លាតូ (Plato) ។ ភាពខុសគ្នារបស់អារីស្តូត ទៅនឹងលោកគ្រូរបស់ខ្លួន គឺមកពីប្រភពមូលដ្ឋាននៃទស្សនះវិជ្ជាផ្សេងៗគ្នា ដែលជាមូលហេតុធ្វើឲ្យគំនិតនយោបាយ របស់មហាទស្សនះវិទូទាំងពីរនេះ ក៏មិនដូចគ្នាដែរ ។ អារីស្តូត បានកំណត់នូវគោលការណ៍បួនយ៉ាងដំបូងបង្អស់នៃការកកើតគំនិតរូបធាតុ មូលហេតុ និងគោលបំណង ។ អារីស្តូត ខុសពីផ្លាតូត្រង់គិតថា «រូបធាតុកើតមុន រីឯគំនិតកើតក្រោយ» ។ រូបធាតុ និងគំនិតមានលក្ខណៈឯកភាពគ្នា មិនអាចកាត់ផ្តាច់ពីគ្នាបានទេ ។ សម្រាប់អារីស្តូត រូបធាតុជាដំបូងមានលក្ខណៈ អសកម្ម ចំណែកគំនិត មានលក្ខណៈសំខាន់ជាង ហើយគំនិត ដែលអាចកើតឡើងបាន ទាល់តែមានសកម្មភាពជាមួយរូបធាតុ ។ ម្យ៉ាងទៀត សម្រាប់អារីស្តូត ខ្លឹមសារ និងបាតុភូតដែលបានកើតឡើង គឺលោកបានបង្ហាញថា «ខ្លឹមសារ កើតមានឡើងតាមរយៈរូបធាតុនិយម» ។

ស្នាដៃដ៏សំខាន់របស់អារីស្តូត បានបង្ហាញនូវទស្សនះទាន របស់ខ្លួនជាច្រើន ពាក់ព័ន្ធនឹងនយោបាយ ។ ដូចជាផ្លាតូដែរ អារីស្តូត បានចាប់ផ្តើមនូវការបែងចែកលក្ខណៈ នៃរបបនយោបាយ និងទំរង់គ្រប់គ្រងរដ្ឋ ។ ការបែងចែកទំរង់គ្រប់គ្រងរដ្ឋរបស់ផ្លាតូ មានលក្ខណៈខុសគ្នាខ្លះៗ អំពីការបែងចែកទំរង់គ្រប់គ្រងរដ្ឋរបស់អារីស្តូត ។ទស្សនះទានរបស់ផ្លាតូ បានគិតថា «គោលការណ៍សំខាន់របស់រដ្ឋ គឺគុណធម៌» ។ អារីស្តូត បានកំណត់នូវរចនាសម្ព័ន្ធនយោបាយ ដែលមានសម្បទានមានបីប្រភេទ ដោយអាស្រ័យ នឹងគុណធម៌ ហើយកំណត់ ទំរង់នយោបាយដែលមិនមានសម្បទាន ៣ ប្រភេទទៀត ។ ប្រភេទរបបនយោបាយមានសម្បទាន តាមទស្សនះអារីស្តូត គឺរបបរាជានិយម (Monarchy) របបអភិជនាធិបតេយ្យ ឬពួកវណ្ណៈខ្ពស់ (Aristocracy) និងមជ្ឈិមវិថីអធិបតេយ្យ (Polity) ។ហើយរបបនិមួយៗ នៃរបបទាំង ៣ នេះ សុទ្ធតែមានលក្ខណៈ អវិជ្ជមានរបស់វា ។ តាមទស្សនះអារីស្តូត បើរបបរាជានិយម មិនប្រកាន់គោលការណ៍របស់ខ្លួន គឺក្លាយជារបបផ្តាច់ការ (Tyranny) ចំណែកឯរបបអភិជនាធិបតេយ្យ អាចកើតមានឡើង នូវរបបគណាធិបតេយ្យ (Oligarchy) រីឯ Polity វាអាចក្លាយទៅជារបបប្រជាធិបតេយ្យ(Democracy) ។ ភាពខុសគ្នានៃរបបនយោបាយរបស់ផ្លាតូ និងអារីស្តូតបានរកឃើញ នូវរបបនយោបាយមួយទៀតគឺ Polity ។ Polity គឺជារបបនយោបាយមួយ ដែលអំណាចស្ថិតនៅ ក្នុងដៃវណ្ណៈកណ្តាល ។

ការកំណត់របស់អារីស្តូតនេះ បានចេញជារូបរាង នៅក្នុងរបបប្រជាធិបតេយ្យ (Democracy) នៃប្រទេសលោកខាងលិច ដែលសព្វថ្ងៃនេះ គេអាចចាត់ទុកថា ជារបបប្រជាធិបតេយ្យមួយដ៏ខ្ពង់ខ្ពស់ នៅក្នុងលោក ដែលប្រឹងប្រែងដើម្បីសេចក្តីចម្រើនលើគ្រប់វិស័យ នៃសង្គមមនុស្ស (Human Society) ។ ការបែងចែករបបនយោបាយ ដែលអារីស្តូតបានបង្ហាញនៅ ក្នុងស្នាដៃរបស់ខ្លួន ឃើញថាការបែងចែកនេះ អារីស្តូត បានចាប់អារម្មណ៍ ចំពោះរចនាសម្ព័ន្ធរដ្ឋពីរប្រភេទ គឺទម្រង់រដ្ឋសម្បទាន និងទំរង់រដ្ឋមិនសម្បទាន (សម្រាប់អារីស្តូតរបបនយោបាយ និងទំរង់គ្រប់គ្រង រដ្ឋពុំទាន់មានលក្ខណៈច្បាស់នៅឡើយទេ) លោកគិតថា «ទំរង់រដ្ឋសម្បទាន មានលទ្ធភាពដើម្បីបង្កើតនូវគុណធម៌មួយចំនួន រីឯទំរង់រដ្ឋមិនសម្បទានវិញមិនអាច» ។ លោកអារីស្តូត បានកំណត់នូវរបបនយោបាយ និងទំរង់គ្រប់គ្រងរដ្ឋ គឺស្ថិតនៅលើអំណាចពិតប្រាកដ របស់រដ្ឋ ។ អារីស្តូត បានធ្វើការអះអាងថា «ភាពខុសគ្នា រវាងរបបនយោបាយផ្សេងៗ គ្នា គឺនៅត្រង់ចំនួនមេដឹកនាំរដ្ឋ» ។ អារីស្តូត បានបង្ហាញ នូវរបបនយោបាយ និងទំរង់គ្រប់គ្រងរដ្ឋ ដែលស្ថិតនៅក្នុងការកំណត់ និងការបែងចែកប្រភេទទាំងពីរផ្សេងពីគ្នា នៃរចនាសម្ព័ន្ធរដ្ឋគំរូ ។

រដ្ឋគំរូទី១ អារីស្តូត ចាប់អារម្មណ៍ទៅនឹងរដ្ឋគំរូ ដែលមានលក្ខណៈខុសពីគេទាំងអស់ ។ រដ្ឋគំរូ បានផ្តល់ការបំពេញជូនសង្គម នូវស្ថេរភាពយូរអង្វែង ជាអតិមរមា រដ្ឋបែបនេះ សម្រាប់អារីស្តូត ជារដ្ឋគំរូនៅក្នុងការអនុវត្តន៍នយោបាយ ។ អារីស្តូតបានគិតថា «Polity ជារបបនយោបាយគំរូ ព្រោះនៅក្នុងរបបនេះ អំណាចស្ថិតនៅក្នុងការគ្រប់គ្រងដោយវណ្ណៈកណ្តាល» ។ តាមទស្សនៈរបស់អារីស្តូត Polity គឺចំពោះរដ្ឋណា ដែលដឹកនាំប្រកបដោយគតិវិញ្ញូ និងភាពទទួលខុសត្រូវ ចំពោះសកម្មភាពរបស់ខ្លួន ហើយអំណាចស្ថិតនៅក្រោមការគ្រប់គ្រងរបស់មនុស្សភាគច្រើន ។ ហើយទោះជាយ៉ាងណាក្តី ក៏ទម្រង់ Polity នេះខ្លាំងជាងប្រព័ន្ធចុងម្ខាងៗ មានន័យថា ចុងទាំងសង្ខាង គឺមានកម្លាំងស្មើគ្នា ហើយអាចរារាំងសត្រូវបាន ។

រដ្ឋគំរូទី២ អារីស្តូត បានឲ្យតំលៃដោយគិតថា ប្រសើរបំផុត ចំពោះទស្សនៈប្រកបដោយសីលធម៌ នៅក្នុងរបបដែលនៅទីនោះ ប្រជាពលរដ្ឋ ប្រឹងប្រែងដើម្បីបានទទួលនូវកិត្តិយស និងគុណធម៌ នៅក្នុងជីវិត ។ រចនាសម្ព័ន្ធរដ្ឋ ដែលល្អបំផុត គឺជាអង្គការមួយ ដែលផ្តល់នូវលទ្ធភាពដល់មនុស្ស ដើម្បីរស់ក្នុងភាពរុងរឿង និងសុភមង្គល។ រដ្ឋគំរូអារីស្តូត បានចាប់អារម្មណ៍ជាខ្លាំង ចំពោះស្ថានភាពខាងក្រៅ នៃអត្ថិភាពរបស់រដ្ឋ ជាបឋម គឺចំនួនប្រជាពលរដ្ឋ ស្ថានភាពរស់នៅ ជាមួយនឹងការឧបត្ថម្ភគ្រប់បែបយ៉ាង និងស្ថ

នភាពទឹកដី ដើម្បីការពារ និងទប់ទល់សត្រូវឈ្លានពាន ។ តាមទស្សនៈរបស់អារីស្តូត ដែលបានចារនៅក្នុងរបបនយោបាយបានឲ្យយើងដឹងថា ក្នុងចំណោមប្រជាជន ត្រូវបាន បែងចែកចេញពួកសិប្បករ និងឈ្មួញ ព្រោះក្នុងកិច្ចការជីវិតរបស់គេ មិនឆ្លើយតបទៅនឹង គុណធម៌ទេ ដើម្បីមានតួនាទីជាពលរដ្ឋចំតួ គឺមានតែពួកកសិករទេ ។ ប្រជាពលរដ្ឋទាំង អស់ ត្រូវតែចូលរួមជួយគ្នាទៅវិញទៅមក ក្នុងគ្រប់សកម្មភាព និងគ្រប់មធ្យោបាយទាំង អស់ ដែលជាកិច្ចការកសិកម្ម ក្នុងសង្គម ។ អារីស្តូតបានគិតថា «នៅក្នុរដ្ឋគំរូ ត្រូវតែបែង ចែកដីធ្លី ជាសម្បត្តិរួម និងជាសម្បត្តិឯកជន» ។ ចំពោះដីរួម អារីស្តូតបានគិតថា «ត្រូវតែ បែងចែកជាពីរផ្នែក ។ ប្រាក់ចំណូល ដែលបានមកពីចំណែកមួយ ក្នុងចំណោមនេះ ត្រូវគេ ប្រើ សម្រាប់សេចក្តីត្រូវការនៅក្នុងសាសនា រីឯចំណែកទីពីរ គឺសម្រាប់មូលនិធិសង្គម (Social foundation)» ។




ដូច្នេះ ភាពខុសគ្នា ជាមូសដ្ឋាននៃទស្សនទាននយោបាយ របស់អារីស្តូត និងផ្លា តូ ស្ថិតនៅត្រង់ថា អារីស្តូតមានទស្សនៈផ្ទុយនឹងលោកគ្រូរបស់ខ្លួន ត្រង់កន្លែងតថភាព និង

លក្ខណៈជាគំរូ ដែលបានកំណត់តំលៃ និងទិសដៅជាក្រឹតក្រមចំពោះការស្រាវជ្រាវបញ្ហានយោបាយ ។ រដ្ឋគំរូ របស់អារីស្តូត អាចកើតឡើងបាន អាស្រ័យកត្តាពីរយ៉ាង កត្តាទីមួយ គឺស្ថេរភាព និងកត្តាទីពីរ គឺក្រមសីលធម៌ ។ ដូច្នេះ សម្រាប់អារីស្តូត មានរចនាសម្ព័ន្ធរដ្ឋគំរូពីរយ៉ាង ។ ម្យ៉ាង គឺរដ្ឋដែលគិតគូរដល់ប្រយោជន៍រួម នៃវណ្ណៈកណ្តាលជាអតិបរមា ម្យ៉ាងទៀត គឺរចនាសម្ព័ន្ធ សំដៅទៅលើគោលការណ៍បុគ្គលិកភាព ដែលជាមនុស្សប្រកាន់ខ្ជាប់នូវគុណធម៌ ដែលជាទិសដៅនយោបាយសង្គមដ៏សំខាន់បំផុត ជាពិសេស គឺនយោបាយទំនាក់ទំនងគ្នា របស់ប្រជាជន ដែលរស់នៅក្នុងរដ្ឋ ។ និយាយអំពីរដ្ឋអារីស្តូតបានបង្ហាញថា «មនុស្ស គឺជាសត្វចេះធ្វើនយោបាយ ពីធម្មជាតិ ហើយដឹកនាំខ្លួន ការប្រឹងប្រែងជាសភាវគតិ ដើម្បីរស់នៅជាមួយគ្នា រីឯការរីកចម្រើនសង្គម គឺចេញពីគ្រួសារ ទៅជាសង្គម និងពីសង្គមទៅជារដ្ឋ» ។

បើតាមទស្សនៈរបស់អារីស្តូត ដែលបាននិយាយនៅក្នុងស្នាដៃ នៃនយោបាយ គឺរដ្ឋបើតាមលក្ខណៈធម្មជាតិ របស់ខ្លួននាំមុខបុគ្គល ពីព្រោះលក្ខណៈធម្មជាតិ របស់រដ្ឋ មានទីតាំងនៅមុនលក្ខណៈធម្មជាតិរបស់គ្រួសារ និងបុគ្គល ។ កត្តាចាំបាច់ ដើម្បីឲ្យរដ្ឋនាំមុខបុគ្គល តាមអារីស្តូតថា «រដ្ឋ ត្រូវបង្កលក្ខ័ណ្ឌល្អប្រសើរ សម្រាប់ជីវិតពលរដ្ឋ ។ មានតែនៅក្នុងរដ្ឋទេ ទើបមនុស្សអាចមានការជឿនលឿន ពីព្រោះរដ្ឋនាំមក នូវយុត្តិធម៌ និងសីលធម៌ដែលបម្រើ ផលប្រយោជន៍រួមរបស់ប្រជាជន» ។ ត្រង់នេះ អារីស្តូត បាននិយាយអំពីរដ្ឋដូចជាការចុះកិច្ចព្រមព្រៀងសង្គម របស់ប្រជាពលរដ្ឋ ដែលជាទស្សនទាន នៃការកកើតសង្គមពលរដ្ឋ និងនីតិរដ្ឋ ។ ថ្វីបើអារីស្តូត ពុំបានបែងចែក ឲ្យដាច់រវាងរដ្ឋ និងសង្គមពលរដ្ឋយ៉ាងណាក៏ដោយ ក៏អារីស្តូត បាននិយាយថា «រដ្ឋ ត្រូវតែឆ្លុះបញ្ចាំង នូវផលប្រយោជន៍ របស់ប្រជាពលរដ្ឋ» ។ នៅក្នុងទ្រឹស្តីរបស់អារីស្តូត ក៏ដូចជានៅក្នុងទ្រឹស្តីរបស់ផ្លាតូដែរ មានបង្កប់នូវលក្ខណៈផ្តាច់ការនិយម ។ មនុស្ស គឺជាផ្នែកមួយរបស់រដ្ឋ ផលប្រយោជន៍បុគ្គល មិនត្រូវធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍រួម ។ នៅក្នុងការវាយតំលៃរបស់អារីស្តូត ពលរដ្ឋ គឺជាផ្នែកមួយ នៃនយោបាយរួម ។ អារីស្តូតបានហៅពាក្យថាពលរដ្ឋ គឺជាមនុស្សដែលមានសេរីភាព ប៉ុន្តែសេរីភាព មានអត្ថន័យត្រឹមតែពាក្យផ្ទុយ នឹងទាសភាពប្រជាពលរដ្ឋ មិនមែនជាទាសករទេ គ្មាននរណាដឹកនាំគេទេ ។ ពលរដ្ឋធ្វើការងារតែជាយោធា និងការងារទាក់ទង នឹងតុលាការ រីឯការងារធ្វើស្រែចំការ និងផលិតកម្ម គឺជាការងារទាសករ ។ អារីស្តូត បានកំណត់គោលការណ៍របស់អភិជនាធិបតេយ្យ គឺគុណធម៌ ។ គោលដៅរបស់អភិជនាធិបតេយ្យ គឺទ្រព្យសម្បត្តិ ។ គោលដៅរបស់ប្រជាធិបតេយ្យ គឺ

សេរីភាព ។ គឺមានតែ Polity ទេ ដែលចាត់ទុកដូចជាទំរង់គ្រប់គ្រងរដ្ឋគំរូ មានអំណោយផលល្អ ហើយរបបនយោបាយគំរូ ដ៏ល្អបង្ខំទៅដោយសារធាតុបីយ៉ាងខាងលើនេះ ។ ហើយអ្វីទៅ ដែលហៅថា របបនយោបាយអភិជនាធិបតេយ្យត្រឹមត្រូវពិតប្រាដក គឺនៅពេលណា មានការដឹកនាំល្អ បានបង្រួបបង្រួមប្រយោជន៍ទាំងអ្នកមាន ទាំងអ្នកក្រ ។ វណ្ណៈកណ្តាល ដែលកំណត់មុខមាត់របស់ Polity គឺស្ថិតនៅចន្លោះ រវាងអ្នកមាន និងអ្នកក្រ ហើយថែមទាំង ជួយថែរក្សាសង្គម ឲ្យមានស្ថេរភាព និងគ្មានព្រឹត្តិការណ៍បដិវត្តន៍ដូ ច្នេះ ហើយ របបនេះ គឺជារបបដ៏ល្អ រក្សាមិនឲ្យមានចលាចល អស្ថេរភាព ដែលអារីស្តូតបានចាត់ទុកថា ជាទំរង់គ្រប់គ្រងរដ្ឋគំរូ ត្រឹមត្រូវសម្រាប់ជម្រើសរបស់អ្នកដឹកនាំ ៕

## ទស្សនៈរបស់ខុងជឺ (៥៥១-៤៧៩ មុន គ.ស. )

### ជីវប្រវត្តិរបស់ខុងជឺ



ខុងជឺ ជាមហាទស្សនវិទូចិនមួយរូប ដ៏ល្បីល្បាញ មានកិត្តិនាមស្មើ

នឹង សូក្រាត នៅប្រទេសក្រិចដែរ ។ តាមពិតឈ្មោះរបស់លោកគឺ **ជី** ស្ថិតនៅសម្ព័ន្ធលូ ។ ត្រកូលរាជវង្សរបស់លោក ជាអភិជន ហើយបើតាមការស្រាវជ្រាវត្រកូលនេះ មានពូជធារមកពីរាជវង្ស «ចាង» ដែលជាសន្តតិវង្សមួយគ្រប់គ្រងប្រទេសចិន នាសម័យរជ្ជកាលចូវ ។ ដោយសារសង្គ្រាមវាយលុកពីកុលសម្ព័ន្ធចូវ ស្ថិតនៅទិសពាយ័ព្យទន្លេលឿងរាជវង្សចាង ក៏ត្រូវរលាយបាត់បង់ក្នុងសង្គ្រាម ។ឯសមាជិកគ្រួសារ ដែលរួចផុតពីសេចក្ដីស្លាប់វិញ ក៏បន្ទំខ្លួនក្នុងកុលសម្ព័ន្ធ«លូ» ។ខុងជឺ កើតនៅឆ្នាំ ៥៥១ មុន គ.ស ក្នុងទីងងឹត នៃកំហែងថ្មភ្នំមួយ នៃស្រុកចាងតុងក្បែរវាលចិញ្ចឹមសត្វ របស់លោកម្ចាស់នៃសន្តតិវង្សលូ ។ មុនពេលចាប់កំណើត និងថ្ងៃចាប់កំណើតរបស់ខុងជឺ មានអព្ភូតហេតុចំលែក គួរឲ្យកត់សម្គាល់ គឺផ្ទុះភ្នំភ្លើង រន្ទះ រញ្ជួយភ្នំភ្លើង ។ ខុងជឺ កំព្រាឪពុកតាំងពីអាយុ ៣ ឆ្នាំ ហើយមានចិត្តសប្បុរសធម៌ តាំងពីក្មេង តែគាត់រស់ក្នុងទីទល់ក្រ ។ លុះបានអាយុ ២០ឆ្នាំ គាត់បានរៀបការជាមួយនឹងស្រីជនជាតិម៉ុងហ្គោលម្នាក់ ដែលមានកូនប្រុសឈ្មោះលី ។ដោយកាខិតខំស្រាវជ្រាវ ខុងជឺ បានក្លាយជាគ្រូម្នាក់ ដែលចេះដឹងសព្វមុខវិជ្ជា ពិសេសខាងវិជ្ជាពេទ្យ ខុងជឺចេះទស្សន៍ទាយ ជាអ្នកបង្ហាត់បង្រៀន ឲ្យប្រជាជនចិន ចេះសែនព្រេនដូនតា តាមលក្ខណៈនេះគាត់ជាអាចារ្យពេលមានអាពាហ៍ពិពាហ៍ និងវិធីបុណ្យផ្សេងៗ ផងដែរ ។ កិត្តិនាម របស់ខុងជឺល្បីល្បាញពេញស្រុកចាន់ស៊ី ហើយពេលនោះ ទស្សនៈវិជ្ជា បស់ខុងជឺ ក៏ចាប់រីកដុះដាល គេនាំ

គ្នាប្រសិទ្ធិនាម ឲ្យគាត់ថា«ជូ» មានន័យថា«បណ្ឌិត» ចាប់ពីពេលនោះមក ។ នៅអាយុ ៤៩ ឆ្នាំ ខុងជឺត្រូវបានព្រះមហាក្សត្យ តែងតាំងធ្វើជាសេនាបតីធំម្នាក់ក្នុងវាំង ។ ខុងជឺបានផ្សព្វផ្សាយទស្សនះវិជ្ជារបស់គាត់គ្រប់ទិសទីពាសពេញប្រទេសចិន ក្នុងគោលបំណងឲ្យប្រជាជនចិនស្គាល់ យល់ដឹងនូវតំលៃរបស់ខ្លួន និងចង់កែរប្រែរបៀបអប់រំសីលធម៏ តែត្រូវមហាក្សត្រលូជំនាស់ ។ ដោយវិបត្តិនយោបាយខុងជឺ បានភៀសខ្លួនពីស្រុកមួយ ទៅស្រុកមួយ អស់រយះពេល ១៣ ឆ្នាំ ។ ខុងជឺបានវិលត្រឡប់ចូលស្រុកលូវិញ ក្នុងជន្មាយុ ៧០ ឆ្នាំ ។ ខុងជឺ បានផ្សាយទស្សនវិជ្ជា របស់គាត់ អស់រយះពេល ១៣ ឆ្នាំ ក្នុងស្រុកចិនទាំងមូល ព្រមទាំងបើកបង្រៀនដល់សាវ័កទៀតផង ។ ខុងជឺមិនគ្រាន់តែជាគ្រូបង្ហាត់ខ្លួនខ្នាតប៉ុណ្ណោះទេ ថែមទាំង ជាអ្នកដឹកនាំប្រជាជន ឲ្យអនុវត្តន៏នូវទំនៀមទំលាប់ចាស់ ឲ្យរីកចម្រើនឡើងវិញ គេសង្កេតឃើញប្រជាជនចិន ចាប់ប្រើក្រដាស និងជក់ខ្មៅដុសថ្នាំ សម្រាប់សរសេរ និងឲ្យចេះសែនព្រេនដូនតា រាល់ឆ្នាំ តាំងពីសម័យខុងជឺមក ។ គាត់រស់បាន ៣ ឆ្នាំ ក្នុងសំណាក់សាវ័កទាំងឡាយ ហើយបានទទួលមរណភាព ក្នុងឆ្នាំ ៤៧៩ មុន គ.ស ។

## ស្នាដៃទស្សនវិជ្ជារបស់ខុងជឺ

ខុងជឺ បានចងក្រងគម្ពីរឈ្មោះថា«លាវយី» មានន័យថា សិល្បះទាំង ៦ ជាសិល្បះសេរី មានគោលដៅស្វែងរកនូវសេរីភាព ក្នុងនយោបាយ និងសេដ្ឋកិច្ច ។

**ទស្សនវិជ្ជាទាំង ៦ របស់ ខុងជឺគឺ**

**១-គម្ពីរឈ្មោះយី**= និយាយ ពីការផ្ទេរកម្មសិទ្ធិ និងផ្ទេរមរតក ។

**២-គម្ពីរឈ្មោះចេ**=ជាកំណាព្យនិទាន សម្រាប់បម្រើសោភ័ណ្ឌធម្មជាតិ ។

**៣-គម្ពីរឈ្មោះលី**= និយាយ ពីការប្រារព្ធពិធីសែនព្រេនផ្សេងៗ ។

**៤-គម្ពីរឈ្មោះយ៉ូ**= និយាយ ពីបទភ្លេង និងចម្រៀងបណ្ដែតអារម្មណ៍ ។

**៥-គម្ពីរឈ្មោះជូ**=និយាយ ពីប្រវត្តិសាស្ត្រ និងពង្សាវតា នៃប្រទេសចិន ។

**៦-គម្ពីរឈ្មោះឈូសាវ ឬគម្ពីរនិទាយរដូវ**=និយាយ ពីសរទរដូវ ជាប្រវត្តិសាស្ត្រ ជាក់ស្ដែងរបស់សន្តិវង្សលូ ។

ចំពោះទស្សនវិជ្ជា ខុងជឺ បានឲ្យតំលៃ ទៅលើសីលធម៌ មនុស្សធម៌ និងសច្ចធម៌ ។ តាមទស្សនៈ ខុងជឺ នៅក្នុងសង្គម មានមនុស្សពីរប្រភេទ ដែលតែងតែស្វែងរកវត្ថុពីរផ្ទុយគ្នា ។ មនុស្សប្រភេទទីមួយ ជាមនុស្សប្រកបដោយគតិបណ្ឌិត ដែលសុខចិត្តលះបង់គុណប្រយោជន៍ គ្រប់បែបយ៉ាង ដើម្បីស្វែងរកយុត្តិធម៌ និងដើម្បីបណ្ដុះកិត្តិស័ព្ទរបស់ខ្លួន ។ចំណែកមនុស្សប្រភេទទីពីរ ជាប្រភេទមនុស្សសាមញ្ញ ដែលសុខចិត្តលះបង់យុត្តិធម៌ កិត្តិយសដើម្បីស្វែងរកគុណ

ប្រយោជន៍ ។

**ខុងជឺបានបែងចែកទស្សនៈដូចខាងក្រោម**

**មនុស្សធម៌**= ខុងជឺ បានហាមមិនឲ្យធ្វើសង្គ្រាមជាដាច់ខាត ទោះស្ថិក្នុងសភាពបែបណាក៏ដោយ ។ ខុងជឺមើលឃើញសង្គ្រាម ជាប្រភពនៃអមនុស្សធម៌ ។ លោកមិនពេញចិត្តចំពោះអំពើឃោរឃៅអមនុស្សធម៌ ដែលពួកមនុស្ស ធ្វើទៅលើសត្វ និងធ្វើទៅលើមនុស្សគ្នាឯង ដូចករណីកងទ័ព ចាប់ឈ្លើយសង្គ្រាមមកកាត់ដៃ កាត់ជើងបោះទៅលើចុងលំពែង ចាប់មនុស្សយកទៅស្រុះទឹកក្តៅដូចជាស្រុះមាន់ គាបក្បាលពិរុទ្ធជន ឲ្យស្លាប់ដោយទារុណកម្ម ។ល។ អំពើទាំងនេះ សុទ្ធសឹង ជាអំពើអមនុស្សធម៌ ។

**យុត្តិធម៌**= ខុងជឺ មើលឃើញយុត្តិធម៌ ក្នុងរូបភាពពីរយ៉ាង គឺយុត្តិធម៌នៅក្នុងសង្គម និងយុត្តិធម៌នៅក្នុងគ្រួសារ ។ ដំបូងឡើយយុត្តិធម៌ កើតមាននៅក្នុងគ្រួសារជាមុនសិន ក្រោយមក ទើបវារាលដាលដល់សង្គម ។ ខុងជឺ មើលឃើញយុត្តិធម៌ពួនសំងំនៅក្នុងចិត្ត និងកាយវិការរបស់មនុស្ស ។ ហេតុនេះ ដើម្បីឲ្យយុត្តិធម៌សង្គមកើតមានឡើង ជំហ៊ានទីមួយ ត្រូវធ្វើឲ្យមានយុត្តិធម៌ នៅក្នុងគ្រួសារជាមុនសិន ។ ខុងជឺ បានឈរលើទស្សនៈថា «កូនត្រូវស្តាប់បង្គាប់ឪពុកម្តាយនិងរាមច្បងរបស់ខ្លួន» ។

**សីលធម៌**= ខុងជឺ បានបង្គាប់ឲ្យមនុស្សគ្រប់វណ្ណៈទាំងអស់ នៅក្នុង

សង្គម និងគ្រប់ស្រទាប់វណ្ណៈទាំងអស់ នៅក្នុងគ្រួសារ ត្រូវតែហ៊ាន ទទួលនូវកំហុសរបស់ខ្លួន នៅចំពោះមុខគ្រួសារ និងចំពោះមុខច្បាប់ ផងដែរ ។ អ្នកប្រព្រឹត្តល្មើសនឹងច្បាប់ ត្រូវទទួលខុសត្រូវ ទទួល ទារុណកម្ម ឲ្យសមនឹងកំហុស ដែលគេបានសាង ។ ប្រសិនបើកំហុស នោះ ធ្ងន់ដល់ប្រហារជីវិត អ្នកទោស ត្រូវតែហ៊ានធ្វើអត្តឃាតខ្លួនឯង ។ ទស្សនៈ របស់លោកខុងជឺ សង្កត់ធ្ងន់ថា«មនុស្សម្នាក់ៗ ត្រូវមាន ស្មារតីអៀនខ្មាស់ ត្រូវតែចេះយល់នូវអ្វី ដែលត្រឹមត្រូវយុត្តិធម៌ សម្រាប់ជីវិត» ។ខុងជឺ បានបង្កើតសីលធម៌មួយទៀត ហៅថា «ជិន» មានន័យថា«ស្រលាញ់ អ្នកដទៃ» ដោយខុងជឺ មានបំណង ឲ្យអ្នក សិក្សាស្រលាញ់ផលប្រយោជន៍ និងជីវិតអ្នកដទៃ ឲ្យដូចជាស្រលាញ់ ជីវិតរបស់ខ្លួន ។

## សីលធម៌នោះគឺ

-ធ្វើគុណទៅហើយ បើគេតបមកវិញ ចាត់ទុកដូចជាពុំបានធ្វើគុណ ។

-ធ្វើគុណទៅហើយ បើបានផលអាក្រក់វិញ ត្រូវទទួលថា ជាបទ ពិសោធន៍ដោយដៃពីរ ។

-អំពើណា ដែលអ្នកពុំចង់ឲ្យគេធ្វើមកលើរូបអ្នក ចូរអ្នកកុំធ្វើអំពើ នោះទៅអ្នកដទៃ ។

-អំពើណា ដែលអ្នកស្រលាញ់ ចង់បាន ឲ្យគេធ្វើមកលើរូបអ្នក ចូរអ្នក ធ្វើនូវអំពើនោះទៅអ្នកដទៃជាមុនសិន ។

-អំពើណា ដែលធ្វើទៅហើយ បានទទួលផលដល់ខ្លួនឯងហើយ មាន

ទុក្ខដល់អ្នកដទៃ សូមជៀសវាងកុំធ្វើនូវអំពើនោះ ជាដាច់ខាត ។ -បើជួយអ្នកដទៃហើយ បែរជាត្រឡប់មកទទួលទោសវិញ ចូររត់គេចឲ្យផុតពីទុក្ខទោសនោះ ឲ្យបានមុនទុក្ខទោសនោះ មកដល់ ។ -បើធ្វើប្រយោជន៍ហើយ សូមកុំរំលឹកគុណទាំងនោះនៅចំពោះមុខគេឲ្យសោះ បើមិនដូច្នោះទេ ទោះជាគុណប៉ុនភ្នំ ក៏ត្រូវរលាយដែរ ។ -ត្រូវទុកឲ្យអ្នកដទៃ និយាយពីគុណរបស់អ្នកវិញ ទើបប្រសើរជាង ។ -អ្វីដែលអ្នកមិនសប្បាយចិត្ត ចំពោះអ្នកធំធ្វើមកលើរូបអ្នក ចូរអ្នកកុំយកវាទៅអនុវត្តន៍ លើមនុស្សដែលនៅក្រោមបង្គាប់អ្នក ឲ្យសោះ ។

## គុណធម៌របស់ខុងជឺ

គុណធម៌ របស់ខុងជឺ គឺសំដៅលើចិត្តមេត្តា ករុណា និងភាពត្រឹមត្រូវ ។ លោកថា«មនុស្សម្នាក់ៗ នៅក្នុងសង្គម សុទ្ធតែមានកាតព្វកិច្ចដែលគួរធ្វើ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន របស់ពួកគេ ត្រូវប្រកបដោយសីលធម៌ និងភាពត្រឹមត្រូវ» ។ នេះទើបហៅថា«គុណធម៌» ។ តែបើគេធ្វើកិច្ចការទាំងឡាយ ដោយគ្រាន់តែពិចារណា ប៉ុន្តែខ្វះសីលធម៌នោះ សកម្មភាពរបស់ពួកគេ នឹងក្លាយទៅជាសកម្មភាពមិនត្រឹមត្រូវ និងខ្វះគុណធម៌ ។មួយវិញទៀត ខុងជឺ ចាត់ទុកថា «ការគ្រប់គ្រងដោយគុណធម៌ មានលក្ខណល្អប្រសើរ ជាងគ្រប់គ្រងដោយច្បាប់» ។



គាត់រំពឹងថា ការគ្របគ្រងរដ្ឋ ប្រកបដោយគុណធម៌ អាចដំណើរការទៅរួច ថែមទាំងឈានទៅសម្រេចផ្លែផ្កាទៀតផង ។ ការគ្រប់គ្រងល្អ គឺទាល់តែអ្នកគ្រប់គ្រង ធ្វើសង្គមឲ្យមានសណ្តាប់ធ្នាប់ និងជីវភាពរុងរឿង ។ ចង់ឲ្យសង្គមមានសណ្តាប់ធ្នាប់ និងជីវភាពរុងរឿង ត្រូវធ្វើសណ្តាប់ធ្នាប់ និងចេះគ្រប់គ្រងជីវភាពគ្រួសារជាមុនសិន ។មនុស្ស ដែលមានទឹកចិត្តល្អ លុះត្រាតែមានឆន្ទះស្មោះត្រង់ និងមានការអប់រំល្អ ។ នៅពេលដែលមនុស្ស បានទទួលការអប់រំល្អ ហើយ ជីវភាពគ្រួសាររបស់គេ ក៏ត្រូវបានគ្រប់គ្រងល្អដែរ ។ បើជីវភាពគ្រួសារបានគ្រប់គ្រងហើយនោះ នាំឲ្យជីវភាពសង្គម ឬប្រទេសជាតិ មានសណ្តាប់ធ្នាប់ ។ លទ្ធផលចុងក្រោយ គឺពិភពលោកនឹងមានសន្តិភាព ។ ខុងជឺយល់ថា ដើម្បីឲ្យសង្គមមានសណ្តាប់ធ្នាប់ លុះត្រាតែនៅក្នុងសង្គមនោះ មានការប្រតិបត្តិត្រឹមត្រូវ នូវអ្វីដែល

គាត់ហៅថា«ការកែតំរូវ ឲ្យត្រឹមត្រូវតាមឈ្មោះ» នោះជាមុនសិន ។ នេះមានន័យថា«ម្នាក់ៗ ត្រូវតែស្គាល់ឈ្មោះកាតព្វកិច្ច និងតួនាទីរបស់ខ្លួន ឲ្យបានច្បាស់លាស់» ។ ខ្លឹមសារសំខាន់នោះ ឋិននៅត្រង់ថា អ្នកគ្រប់គ្រងគឺអ្នកគ្រប់គ្រង រដ្ឋមន្ត្រីគឺរដ្ឋមន្ត្រី ឪពុកគឺឪពុក កូនគឺកូន ។ល។ គ្រប់ឈ្មោះទាំងអស់ គឺសុទ្ធតែឋានៈ មានកាតព្វកិច្ច តួនាទី និងមុខងារ ខុសៗ គ្នា ។ បើឈ្មោះណាមួយ បំពេញមុខងាររបស់ខ្លួនមិនត្រឹមត្រូវ អ្នកនោះមិនអាចក្លាយទៅជាបុគ្គល ដ៏ល្អតាមឋានៈនោះឡើយ ។ ឧទាហរណ៍ថាៈ បើអ្នកដឹកនាំ គ្រប់គ្រងគេ មិនខ្វល់ខ្វាយចំពោះវិជ្ជា ឬវិធីដឹកនាំគ្រប់គ្រងនោះទេ ទោះបីជាអ្នកនោះ មានប្រជាប្រិយភាពប៉ុណ្ណាក៏ដោយ ក៏គេនោះមិនអាច ជាអ្នកដឹកនាំ ដ៏ល្អបានដែរ ។

ដូចនេះ ឃើញថា ទស្សនៈនយោបាយ របស់ខុងជឺ ពិតជាបានរួមវិភាគទាន យ៉ាងធំសម្បើម ក្នុងការរុញច្រានទ្រឹស្តីនយោបាយ បែបទស្សនវិជ្ជា ដែលមានសីលធម៌ ឲ្យមានភាពរីកដុះដាលឡើង ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺខុងជឺ មិនបានប្រើប្រាស់កម្លាំងខាងក្រៅ មកជួយរៀបចំ និងដោះស្រាយបញ្ហា ក្នុងសង្គមមនុស្សទេ ។ តែលោកប្រើក្បួនច្បាប់ គុណធម៌ និងសីលធម៌ ធ្វើជាមូលដ្ឋានសម្រាប់ដោះស្រាយបញ្ហា ក្នុងសង្គមមនុស្សទៅវិញ ។

ទស្សនៈរបស់ John Locke ( ១៦៣២-១៧០៤ នៃគ.ស. )

## ជីវប្រវត្តិរបស់ Jonh Locke



លោក John Locke ជាទស្សនវិទូ និងជាអ្នកទ្រឹស្ដីនយោបាយ ជនជាតិអង់គ្លេស ។គាត់កើតនៅថ្ងៃទី ២៩ ខែសីហា ១៦៣២ នៃគ.ស. នៅក្នុងភូមិ Wrington ក្រុង Somerset ខាងត្បូងឈៀងខាងលិច នៃប្រទេសអង់គ្លេស ។ ហើយបានទទួលមរណកាលនៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ ១៧០៤ នៃគ.ស. ក្នុងជន្មាយុ ៧២ ឆ្នាំ ក្នុងក្រុង Essex ភាគខាងកើត នៃប្រទេសអង់គ្លេស ។ គាត់ក៏ជាស្ថាបនិកទ្រឹស្ដីសេរីនិយម (Liberalism)ម្នាក់ដែរ ។

## ទស្សនះវិជ្ជារបស់ John Locke

ទស្សនៈនយោបាយរបស់លោក John Locke ដែលធ្វើឲ្យលោកមានកិត្យានុភាពល្បីល្បាញ ក្លាយជាអ្នកនយោបាយវិទ្យា គឺស្នាដៃ «អត្ថាធិប្បាយពីរនៃការដឹកនាំរដ្ឋ (Two Treatises of Government)» ដែលបានបោះពុម្ពផ្សាយលើកទីមួយ នៅក្នុងឆ្នាំ ១៦៩០ ។ នៅក្នុងស្នាដៃលោក John Locke បានបង្ហាញយ៉ាងច្បាស់ នូវការកំណត់មូលន័យ នៃសេរីនិយម ដូចជា «បុគ្គលភាព» «សង្គម» «រដ្ឋ» ហើយបានដាក់ «បុគ្គលភាព» ឲ្យខ្ពស់ជាង «សង្គម» និង «រដ្ឋ» ។ ពោលគឺបានបកស្រាយ អំពីបញ្ហារបស់មនុស្ស តាមសភាពធម្មជាតិ ការកកើតសង្គម និងការកកើតរដ្ឋ ។ «អ្វីដែលមាននៅក្នុងគំនិត គឺអ្វីដែលធ្លាប់មានក្នុងពិសោធន៍» នេះជាការអះអាងរបស់ John Locke ។ យោងតាមទស្សនៈរបស់លោកJohn Locke ថា «មនុស្សមានសិទ្ធិរស់ សេរីភាព កម្មសិទ្ធិ» នេះជាលក្ខណៈ ពិសេសរបស់មនុស្ស ដែលមានមកតាំងពីកំណើត ។ លោក John Locke មានការចាប់អារម្មណ៍ ទៅលើបញ្ហាកម្មសិទ្ធិជាឯកជន ចាត់ទុកជាច្បាប់ធម្មជាតិរបស់មនុស្ស ហើយការសន្សំទ្រព្យសម្បត្តិ អាចផ្ដល់លទ្ធភាពឲ្យមនុស្សផ្គត់ផ្គង់ចិញ្ចឹមខ្លួនឯង និងគ្រួសារ នូវអ្វីដែលខ្លួនចាំបាច់ ។ ប៉ុន្តែនៅពេលដែលមនុស្សមាននូវអ្វីជាចាំបាច់ហើយនោះ គេនឹងយកចិត្តទុកដាក់ ថែមទាំងធ្វើឲ្យរីកចម្រើននូវទ្រព្យសម្បត្តិរបស់គេបន្ថែមទៀត ។ តែទោះជាយ៉ាងណាក៏ដោយ ក៏លោក John Locke មិនធ្ងន់ តែកម្មសិទ្ធិជារបស់ឯក

ជនតែម្យ៉ាងនោះទេ ថែមទាំងរិះរកមធ្យោបាយ ដើម្បីរក្សាកម្មសិទ្ធិដែលជាធាតុចាប់ផ្ដើម របស់សង្គមសេរីនិយម ។

លោក John Locke យល់ថា «រដ្ឋ ត្រូវមានស្ថានភាពជាអ្នកនាំមុខសង្គម» ។រដ្ឋ ជាយន្តការ មានលទ្ធភាព និងប្រសិទ្ធិភាព ការពារយុត្តិធម៌ ។ ចំណែកការរស់នៅក្នុងធម្មជាតិ មានលក្ខណៈខុសពីរដ្ឋ ។ លោក John Locke បានសរសេរថា «ដោយឈរលើវិចារណញ្ញាណមនុស្សបានសន្មតគ្នាដើម្បីអនុវត្តន៍ច្បាប់ ដោយឆ្ពោះទៅរកគោលការណ៍ នៃកិច្ចព្រមព្រៀងគ្នា ដោយរួមជាសង្គម (Social Contract) ហើយបង្កើតបានជារដ្ឋ» ។John Locke គឺជាអ្នកបង្កើតទ្រឹស្ដីបែងចែកអំណាច ដែលជាមូលដ្ឋាននៃនីតិរដ្ឋ ។ និយាយជារួម ទេពកោសល្យដែលបានបង្ហាញក្នុងស្នាដៃរបស់លោកមានឥទ្ធិពលយ៉ាងខ្លាំង ទៅលើវិទ្យាសាស្ត្រនយោបាយ និងទស្សនៈវិជ្ជានយោបាយ ក្នុងសតវត្សទី ២០ និងទី ២១ ។ជីវិតរបស់លោក បានឆ្លងកាត់ព្រឹត្តិការណ៍ជាច្រើន ចំពេលដែលប្រទេសអង់គ្លេស មានបដិវត្តន៍ប្រឆាំង នឹងវិទ្យាសាស្ត្រ ។ដោយឈរលើទ្រឹស្ដីច្បាប់ធម្មជាតិ John Locke បានសិក្សាពីស្ថានភាពរបស់មនុស្សក្នុងតំណាក់កាលដំបូង គឺចាប់ពីពេលដែលរដ្ឋមិនទាន់ចាប់បដិសន្ធិ ។ ចំណុចថ្មីមួយ ដែល John Locke រកឃើញគឺកម្មសិទ្ធិឯកជនដែលកើតមានមុនការកកើតសង្គម ឬកកើតនៃអំណាចនយោបាយ ។កម្មសិទ្ធិឯកជន កើតមាននៅក្នុងសភាពធម្មជាតិ ។កម្មសិទ្ធិឯកជន ជាសារធាតុ មិនអាចញែកចេញពី

មនុស្សបានទេ ព្រោះកម្មសិទ្ធិជាសមិទ្ធិផល នៃការងាររបស់មនុស្ស ។ តាមរយៈ បទពិសោធន៍ទ្រឹស្តីធម្មជាតិ ហើយនឹងតាមរយៈ ការបកស្រាយស្តីពីការគ្រប់គ្រងរដ្ឋ John Lockeបានពន្យល់ថា «ដំបូងមនុស្ស ត្រូវការចំណីអាហារ ផ្លែឈើ បរិភោគចំអែតក្រពះ» ។ គាត់ថា «ដោយសារតែកម្លាំងពលកម្មរបស់គេ មនុស្សត្រូវបេះផ្លែឈើឲ្យបានច្រើន ដាំដើមឈើហូបផ្លែ ឲ្យបានច្រើននេសាទ ឲ្យបានច្រើន ឬផលិតគ្រឿងឧបភោគបរិភោគឲ្យបានច្រើន ដើម្បីទុកសម្រាប់ពេលក្រក្សត់» ។ ដូច្នេះ ចេញពីផលិតផលដែលគេខំផលិតសម្រាប់ទុកបរិភោគនេះឯង ដែលទាំងនេះជាប្រភព ឬជាហេតុនាំឲ្យកើតមានកម្មសិទ្ធិ ។កម្មសិទ្ធិពីធម្មជាតិ របស់មនុស្សដែល John Lockeលើកមកបង្ហាញផងដែរ គឺសិទ្ធិ និងសេរីភាព ។ គាត់យល់ថា «មនុស្ស មានវិចារណញ្ញាណដែលបង្ខំឲ្យគេមានការងារ ឬករណីយកិច្ចជាច្រើន ហើយកិច្ចមុនដំបូងគេបង្អស់នោះ គឺការរក្សាអាត្មាខ្លួនឯងជាមុនសិន ។ បើការរក្សាខ្លួនឯងជាករណីយកិច្ចនោះក៏បញ្ជាក់ឲ្យឃើញថា មនុស្សម្នាក់ៗ មានសិទ្ធិលើខ្លួនឯងផ្ទាល់គេ គឺជាកម្មសិទ្ធិរបស់ខ្លួនគេផ្ទាល់ ។ពីធម្មជាតិ គេមានខ្លួនគេជាប់ជាមួយនឹងកម្លាំងការងារ ដូច្នេះអ្វី ដែលកើតចេញពីកម្លាំងរបស់គេ ក៏ជាកម្មសិទ្ធិរបស់ខ្លួនគេដែរ» ។

## លក្ខណៈជាកម្មសិទ្ធិមាន ៣ ប្រការ

១-ការយកមកធ្វើជារបស់ខ្លួន វាត្រឹមត្រូវតាមធម្មជាតិ ព្រោះគេជាម្ចាស់លើខ្លួនឯង ជាម្ចាស់លើរូបកាយខ្លួន ហើយអ្វីដែលកើតចេញពីរូបកាយ របស់ខ្លួន ក៏ជាមរតករបស់ខ្លួនដែរ ។

២-ការចេញពីសភាពធម្មជាតិ មិនមែនជាការចាំបាច់ដាច់ខាតនោះទេ តែការចូលមករស់ នៅក្នុងសភាពជាសង្គម វាមានការធានាមួយខ្ពស់ជាង។ សង្គមមួយ ដែលមិនមានគោលដៅ សម្រាប់ការថែរក្សាកម្មសិទ្ធិ ក៏មិនអាចមានឈ្មោះថាសង្គមនោះទេ។ សារៈសំខាន់របស់សង្គម គឺការពារកម្មសិទ្ធិ។

៣-មានតែកិច្ចព្រមព្រៀង ដោយស្ម័គ្រចិត្ត រវាងបុគ្គលជាម្ចាស់កម្មសិទ្ធិ ពោលគឺកិច្ចព្រមព្រៀងសំដៅធានាដល់កម្មសិទ្ធិ ដែលបង្កើតបានជាសង្គមនយោបាយនោះ ។

## លក្ខណៈធម្មជាតិរបស់មនុស្ស

John Locke បានបកស្រាយស្ថានភាពធម្មជាតិ របស់មនុស្សជាស្ថានភាពដែលមានសេរីភាពគ្រប់គ្រាន់ ក្នុងការទំនាក់ទំនង រវាងបុគ្គល និងបុគ្គល ។ ស្ថានភាពធម្មជាតិ ជាស្ថានភាព ដែលពោរពេញទៅដោយសមភាពទាំងអំណាច ទាំងសិទ្ធិ សុទ្ធតែស្មើៗ គ្នា គ្រប់បុគ្គលទាំងអស់ ដោយមិនមានបុគ្គលណាម្នាក់ មានសិទ្ធិអំណាចច្រើនជាងអ្នកដទៃនោះទេ ហើយមានសិទ្ធិសេរីភាព មិនអាចមិនអាចកាត់ផ្តាច់ពីបុគ្គលឡើយ ក្នុងស្ថានភាពធម្មជាតិ ។ សភាពធម្មជាតិ ជាកន្លែងដំបូង ដែលបានផ្តល់សិទ្ធិ ឲ្យមនុស្ស ។ ស្ថានភាពធម្មជាតិ មាន

សភាពសន្តិភាព និងជាសភាពដែលមនុស្សមានសុឆន្ទៈ ចង់ជួយគ្នាទៅវិញទៅមក ជាសភាពដែលមានវិចារណញ្ញាណ អាចយល់ដឹងពីច្បាប់ធម្មជាតិបាន និងជាសភាពដែលមនុស្សចេះសម្របសម្រួល នូវអាកប្បកិរិយារបស់ខ្លួន ទៅនឹងច្បាប់ធម្មជាតិ ។ តាមតែសភាពធម្មជាតិ ក៏ជាសភាពដែលខ្វះខាត ព្រោះមិនមានការកំណត់ច្បាប់ និងប្រកាសឲ្យប្រើប្រាស់ច្បាប់សម្រាប់អ្នកទាំងអស់គ្នាឡើយ ។ ក្នុងសភាពធម្មជាតិ ខ្វះនូវអំណាចតុលាការ សម្រាប់ទប់ស្កាត់ មិនឲ្យមានការសងសឹកគ្នា ការដែជកគ្នា យកចាញ់ឈ្នះ តាមលក្ខណៈជាក់ស្តែងឡើង ដូចរូបភាពជាកូនក្តីផង ជាមេធាវីផង ជាចៅក្រមផងនោះឡើយ ។ ប្រព័ន្ធរស់នៅក្នុងសភាពធម្មជាតិ មិនអាចឋិតនៅបាន ដូច្នេះកម្មសិទ្ធិរបស់មនុស្ស មិនអាចរក្សាទុកល្អបានទេ បើគ្មានសង្គម ក៏គ្មានរដ្ឋដែរ ។ ដូច្នេះ សង្គមជាអ្នកថែរក្សា ជាអ្នកជួយសម្រួលស្ថានភាពដល់កម្មសិទ្ធិទាំងនោះ ។ ធម្មជាតិនេះ មានសារៈសំខាន់ណាស់ពីព្រោះសេរីភាពជាសម្បត្តិ ដ៏ពិសិដ្ឋរបស់មនុស្ស កើតចេញពីធម្មជាតិហ្នឹងឯង ។ John Locke យល់ថា «តាមធម្មជាតិមនុស្ស កើតមកនាំមកជាមួយ នូវគំនិតចង់បានកម្មសិទ្ធិឯកជន។កម្មសិទ្ធិឯកជន ចាក់ឫសយ៉ាងជ្រៅ ក្នុងសភាពធម្មជាតិ ។ការដែលមនុស្ស ចង់បានកម្មសិទ្ធិនោះ គឺមិនមានអ្វីប្រឆាំង នឹងសង្គមដែរ ។ តែផ្ទុយទៅវិញ កម្មសិទ្ធិឯកជននេះ បានជួយរុញច្រានសង្គម ឲ្យមានសំទុះទៅមុខ ជាមួយនឹងវឌ្ឍនភាពយ៉ាងឆាប់រហ័ស» ។

## មូលហេតុដែលនាំឲ្យមនុស្សត្រូវការកិច្ចព្រមព្រៀងគ្នាជាសង្គម

**ទី១**-មនុស្ស ចូលមករួមគ្នាជាសង្គម មូលហេតុ គឺព្យាយាមរកសន្តិភាព សុវត្ថិភាព និងការថែរក្សាសម្បត្តិ កម្មសិទ្ធិរបស់ខ្លួនឲ្យគង់វង្ស ។ ដូច្នេះដើម្បីទទួលបាន នូវសុវត្ថិភាព ចាំបាច់ត្រូវការច្បាប់និងតុលាការ ក្នុងសង្គមនោះ ។ ក្នុងសភាពធម្មជាតិ បើមានការរំលោភបំពានណាមួយកើតឡើង ក៏ពុំទាន់មានការដាក់ទណ្ឌកម្មឲ្យសមស្របទៅនឹងឆន្ទៈរបស់ជនរងគ្រោះដែរ ។ ដូច្នេះ ការដាក់ទណ្ឌកម្មគឺធ្វើឡើងតាមគំនិតផ្តួចផ្តើម នៃជនរងគ្រោះនិងប្រជារាស្ត្រទូទៅ ។ ការស្វែងរកយុត្តិធម៌ ក្នុងសភាពធម្មជាតិ នៅមានលក្ខណៈជាការស្វែងរកសម្រាប់បុគ្គលម្នាក់ៗ ដែលជាអ្នករងគ្រោះនោះ ឬទង្វើនោះធ្វើតាមកំហឹងផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ យ៉ាងនេះ គេឲ្យឈ្មោះថា «យុត្តិធម៌ឯកជន» ។ ក្នុងករណីជនរងគ្រោះ មិនមានសមត្ថភាព និងលទ្ធភាពស្វែងរកយុត្តិធម៌នោះ ពួកគេត្រូវបិននៅក្នុងជនរងគ្រោះអយុត្តិធម៌ ។ John Locke មើលឃើញថា «ក្នុងសភាពបែបធម្មជាតិមនុស្សទាំងឡាយមិនត្រូវបានការពារដោយច្បាប់ ពីសំណាក់ការរំលោភបំពានឡើយ ព្រោះមនុស្ស ពុំទាន់បានបង្កើតអង្គការ រៀបចំសណ្តាប់ធ្នាប់សង្គម និងការដាក់ទណ្ឌកម្ម ទៅលើបទល្មើសនៅឡើយ ។ ដោយចង់បញ្ចប់នូវជម្លោះពីម្នាក់ទៅម្នាក់ និងទទួលបាននូវយុត្តិធម៌នោះ ទើបមនុស្សទាំងឡាយ យល់ព្រមគ្នានឹងគ្នា បង្កើយឲ្យមានជា

អង្គការសង្គមមួយដែលអាចការពារជីវិតបុគ្គល និងសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ពួកគេ ។

**ទី២**-ហេតុផល ដែលតំរូវឲ្យមនុស្សរួបរួមគ្នា ជាសង្គមតូចៗ ឬធំៗ គឺជួយកាត់បន្ថយនូវបន្ទុកនៃការលំបាក។ ដូចនេះ ចាំបាច់បង្កើតវត្ថុដែលតំណាងឲ្យសម្ភារៈពោល គឺពាកើព័ន្ធនឹងការប្រើប្រាស់រូបិយប័ណ្ណនេះ ក្នុងគោលបំណងរក្សានូវកម្មសិទ្ធិផ្ទាល់ខ្លួន ។ នេះជាកត្តាចម្បង ដែលបង្ហាញឲ្យឃើញថា មនុស្សកំពុងតែដកខ្លួនបន្តិចម្តងៗឲ្យឃ្លាតឆ្ងាយពីជីវភាពបែបធម្មជាតិ ។ ចរន្តនេះ បានធ្វើឲ្យមនុស្ស ក្នុងសង្គមមានភាពខុសប្លែកពីគ្នាកាន់តែខ្លាំង។ដូច្នេះ រដ្ឋគឺជាទីកន្លែងបង្អែក ជាកន្លែងដែលមានសុវត្ថិភាព មានសណ្តាប់ធ្នាប់ មានច្បាប់ ហើយក៏ជាក្តីសង្ឃឹមរបស់គេនាពេលអនាគតដែរ ។

**ទី៣**-មនុស្ស បានទទួលផលប្រយោជន៍ ពេលគេចាកចេញពីសភាពធម្មជាតិ គឺដោយសារគេមានបញ្ហាសន្តិសុខ បញ្ហាចាញ់ប្រៀប ហើយគេទាំងអស់គ្នា តែងគិតថា គេនឹងបានស្រួលជាងនេះ ប្រសិនបើមានច្បាប់ជា ធរមានមានចៅក្រមសម្រាប់បកស្រាយច្បាប់ និងអនុវត្តន៏ច្បាប់នោះផង ។

**ទី៤**-ដើម្បីបញ្ចប់សង្គ្រាម មិនចេះឈប់ឈររវាងមនុស្ស និងមនុស្ស ជាបុគ្គលជាក្រុម និងដើម្បីការពារជីវិតបុគ្គលនោះឯង ។

**ទី៥**-មនុស្ស ចាកចេញពីសភាពធម្មជាតិ មករស់នៅក្នុងសភាពបែបថ្មី ក្នុងរដ្ឋនេះ សុទ្ធតែមានមូលហេតុបានន័យថា បើគ្មានភ្លើង ក៏

គ្មានផ្សេងដែរព្រោះកាលណាកម្មសិទ្ធិរបស់ពួកគេ កាន់តែសម្បូរ ក៏ធ្វើឲ្យពួកគេកាន់តែមានវិសមភាពធំធេងជាងមុន។ សុវត្ថិភាពរបស់ពួកគេ ក៏កាន់តែត្រូវបានទទួលការគំរាមគំហែង ។ច្បាប់ដែលបានអនុម័តនៅក្នុងរដ្ឋ ចាំបាច់ត្រូវតែការពារសុវត្ថិភាពសង្គម និងរដ្ឋខ្លួនឯងតែម្តង ។ តាមទស្សនៈរបស់លោក John Locke រដ្ឋមានតួនាទីសំខាន់ គឺដាក់ទណ្ឌកម្មដល់អ្នករំលោភច្បាប់ ក្រៅពីនេះរដ្ឋមានតួនាទីផង ដែរក្នុងការធានាឲ្យមាននូវសិទ្ធិសេរីភាព សមភាព និងសុវត្ថិភាពរបស់ពលរដ្ឋ ។រដ្ឋ គឺជាអង្គការរបស់អ្នកមានសិទ្ធិដែលចង់បានមធ្យោបាយដ៏មានប្រសិទ្ធិភាព ដើម្បីថែរក្សាកម្មសិទ្ធិ ដែលគេរកបានសមស្របទៅ នឹងស្ថានភាពធម្មជាតិរបស់ពួកគេ ។ ក្នុងន័យនេះ រដ្ឋគឺគ្រាន់តែជាឧបករណ៏សម្រាប់បម្រើកម្មសិទ្ធិតែប៉ុណ្ណោះ ។

## ការបែងចែកអំណាចរបស់ John Locke

១-អំណាចនីតិបញ្ញត្តិ ស្ថិតក្នុងដៃសភា ។

២-អំណាចនីតិប្រតិបត្តិ ស្ថិតក្នុងដៃរដ្ឋាភិបាល តុលាការ និងយោធា ។

៣-អំណាចសហព័ន្ធ ស្ថិតក្នុងដៃស្តេច និងរដ្ឋមន្ត្រីនានា ។

ស្តេចជាប្រមុខនៃអំណាចនីតិប្រតិបត្តិ និងអំណាចសហព័ន្ធ ។ អភ័យឯកសិទ្ធិរបស់រដ្ឋាភិបាល ត្រូវបានកំណត់ក្នុងច្បាប់ ។

អំណាចនិតិបញ្ញត្តិ ជាអំណាចកំពូល ក្នុងចំណោមអំណាចទាំងបី ។ អំណាចនិតិបញ្ញត្តិ និងអំណាចនិតិប្រតិបត្តិ មិនត្រូវស្ថិតនៅក្នុងដៃ

របស់បុគ្គលណាមួយឡើយ ព្រោះបើបុគ្គលនោះ យកអំណាចនោះទៅប្រើសម្រាប់ផលប្រយោជន៍បុគ្គល ពុំបានបម្រើផលប្រយោជន៍រួមទេ នឹងធ្វើឲ្យកើតមានរបបផ្តាច់ការ ។ ដូច្នេះការបែងចែកអំណាចជាវិធីសាស្រ្ត ជៀសវាង មិនឲ្យកើតមានឡើង នូវការប្រើអំណាចតាមទំនើងចិត្តបែបអាជ្ញាព្រឹត្តិ ដែលជាកត្តា មិនធានាដល់សិទ្ធិសេរីភាព និងកម្មសិទ្ធិរបស់ពលរដ្ឋឡើយ ។បន្ថែមលើការបែងចែកអំណាចនេះ John Locke បានចាត់ទុកនូវវិធានការណ៍ពីរផ្សេងទៀត ដើម្បីឲ្យរដ្ឋស្គាល់តួនាទីរបស់ខ្លួននៅក្នុងសង្គម ។

## វិធានការណ៍ទាំងពីរនោះគឺ

១-ត្រូវបែងចែកសាសនា ឲ្យដាច់ពីរដ្ឋ ឬនិយាយម្យ៉ាងទៀតថា បែងចែកអំណាចសាសនា ឲ្យដាច់ពីអំណាចរដ្ឋ ។

២-ត្រូវរក្សាសិទ្ធិតស៊ូចំពោះការគាបសង្កត់ ។ចំណែកឯការបះបោរ បាតុកម្ម កូដកម្ម ។ ល ។ វិញមានផលជាអវិជ្ជមានខ្លាំងណាស់ ប្រសិនបើរដ្ឋ មិនបានបំពេញករណីយកិច្ចរបស់ខ្លួននោះទេ ។John Lockeប្រឆាំងនឹងរបបរាជានិយមផ្តាច់ការ ដែលយកពន្ធដារតាមទំនើងចិត្តរឹបអូសយកកម្មសិទ្ធិរំលោភលើសេរីភាព ។ ល ។ លើសពីនេះ អំណាចផ្តាច់ការ ឬរាជានិយមផ្តាច់ការ រឹតតែធ្វើឲ្យ John Locke កាន់តែព្រួយបារម្ភណ៍ថែមទៀត ។ដូច្នេះគំនិតរបស់ John Locke ចង់ឲ្យវត្តមានរដ្ឋ ដែលអនុញ្ញាត និងថែរក្សា ឲ្យមាននូវកម្មសិទ្ធិឯកជន ។ ដូច្នេះទស្សនះរបស់គាត់ផ្តោតខ្លាំងទៅលើអំណាច និងកម្មសិទ្ធិឯកជន

។ ចំណុចទាំងពីរ នេះវាត្របាញ់ចូលគ្នា ក្នុងទស្សនៈវិស័យវឌ្ឍនភាពសេដ្ឋកិច្ច ដែលជាកត្តាដ៏សំខាន់ ដែលត្រូវលើកឡើង ជាបញ្ហាក្នុងបច្ចុប្បន្ន។

# របបប្រជាធិបតេយ្យ

## និយមន័យពាក្យថា «ប្រជាធិបតេយ្យ»

ពាក្យថា «ប្រជាធិបតេយ្យ» ភាសាអង់គ្លេសថា «Democracy» ភាសាក្រិចមាន ២ ពាក្យថា «Demos» មានន័យថា «ប្រជាជន» និងពាក្យថា «Kratos» មានន័យថា «អំណាច» កាលបើរួមពាក្យទាំងពីរនេះចូលគ្នាមានន័យថា «អំណាចរបស់ប្រជាជន» ឬថា «ប្រជាជនជាម្ចាស់នៃអំណាច» ។

ចំណែកភាសាខ្មែរ ដែលមានមូលដ្ឋាន មកពីភាសាបាលី និងភាសាសំស្រ្កឹតវិញថា «ប្រជាធិបតេយ្យ» ញែកចេញជា ២ ពាក្យ គឺ «បជា» ឬ «ប្រជា» មានន័យថា « ពួកសត្វ» ឬ «ប្រជាជន» និងមួយពាក្យទៀតថា «អធិបតេយ្យ» មានន័យថា «ភាពជាធំ» ឬ« អំណាច» រួមទាំងពីរពាក្យនេះ ចូលគ្នា ទៅជា «ប្រជាធិបតេយ្យ» មានន័យថា «ប្រជាជនជាធំ» ឬ «ប្រជាជនជាម្ចាស់ នៃអំណាច» ។ ចំណែកនៅក្នុងវចនានុក្រម របស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ដែលបោះពុម្ពផ្សាយ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យថា «ប្រជាធិបតេយ្យ» មានន័យថា «ភាពនៃប្រទេស ដែលមានប្រជារាស្ត្រ ជាអធិបតី គឺប្រទេស ឬរដ្ឋបាល ដែលមានប្រជាជនជាធំ ក្នុងការជ្រើសរើសតំណាង របស់ខ្លួន ឲ្យជាអ្នកសម្រេចកិច្ចការក្នុងប្រទេស » ។

ពិតណាស់ សមដូចលោករូស្សូអ៊ូ (Rousseau) ជាទស្សនៈ វិទូបារាំង នាសតវត្សទី ៨ បានពោលថា «គោលការណ៍ របស់ប្រជាធិបតេយ្យ គឺប្រជាជនទាំងមូល ជាម្ចាស់ នៃអធិបតេយ្យ ហើយប្រជារាស្ត្រខ្លួនឯង ជាអ្នកប្រើប្រាស់អធិបតេយ្យនោះ» ។ ក្នុងន័យនេះ ប្រធានាធិបតីទី ១៦ របស់សហរដ្ឋអាមេរិក គឺលោក Abraham Lincoln បានពោលថា « រដ្ឋាភិបាល (អំណាច) ជារបស់ប្រជាជន ដោយប្រជាជន និងដើម្បីប្រជាជន» ។

ដូច្នេះបញ្ជាក់ឲ្យឃើញថា រដ្ឋាភិបាល ដែលមានអំណាច បានក្លាយជាមេដឹកនាំ និងបានភាពជាធំ គឺប្រជាជន ជាអ្នកប្រគល់អំណាចឲ្យ ដើម្បីដឹកនាំរដ្ឋ ឬប្រទេសជំនួសពួកខ្លួន (Representative) ដោយខ្លួនមិនចាំបាច់មកអង្គុយក្នុងសភាមិនចាំបាច់សម្រេច នូវរាល់កិច្ចការនានា រវាងរដ្ឋមួយ ទៅរដ្ឋមួយផ្សេងទៀត (Foreign Affairs) ដូចជា ការចុះសន្ធិសញ្ញានានា (Treaties) ការប្រកាសង្គ្រាម  ការចរចារ (Negotiation) ឬការស្វែងរកសន្តិភាព ដោយផ្ទាល់ឡើយ ព្រោះគេមានប្រមុខរដ្ឋរបស់ពួកគេ ដែលគេជ្រើសរើសរួចហើយ ដោយសម្លេងភាគច្រើន ឲ្យចេញមុខជំនួស ។ មេដឹកនាំ ឬរដ្ឋាភិបាលនោះ ជាអ្នកធានា ឬនាំមកនូវសមភាព តុល្យភាព សុវត្ថិភាព ស្ថេរភាព ភាតរភាព សិទ្ធិសេរីភាព ទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកនយោបាយ និងដឹកនាំរដ្ឋទៅកាន់ភាពរុងរឿង ដោយទទួលបាននូវកិត្យានុភាព និងទទួលស្គាល់លើឆាកអន្តរជាតិឲ្យដល់ម្ចាស់អំណាច គឺពលរដ្ឋ ដែលមានវត្តមាននៅក្នុងសង្គម ឬនៅក្នុងរដ្ឋនោះៗ ។ ដូច្នេះអំណាចនេះ គឺជារបស់ប្រជាជន ដោយប្រជាជន និងដើម្បីប្រជាជន ។

## ប្រជាធិបតេយ្យមាន២ប្រភេទគឺ

១-ប្រជាធិបតេយ្យដោយត្រង់ (Directive Democracy) មានន័យថា ប្រជាជនដែលរស់នៅក្នុងសង្គម ឬរដ្ឋនោះៗ មានសិទ្ធិសេរីភាពស្មើៗ គ្នា ក្នុងការរស់នៅ ក្នុងការប្រកបមុខរបរ មិនថាផ្នែកសេដ្ឋកិច្ច មិនថាផ្នែកនយោបាយ គឺគ្រប់គ្នារួមគ្នា ជាកម្លាំងមួយ ជួយអភិវឌ្ឍន៍សង្គម ឬរដ្ឋ ថែមទាំងជួយដោះស្រាយរាល់បញ្ហា ដែលពួកខ្លួនត្រូវប្រឈមមុខទៀតផង ។ ប្រជាធិបតេយ្យបែបនេះ ច្រើនឃើញមាននៅ ក្នុងសម័យក្រិចបុរាណ ។ សព្វថ្ងៃ ប្រជាធិបតេយ្យដោយត្រង់ (Directive Democracy) នេះ មិនឃើញមានវត្តមាននៅលើប្រទេសនានាឡើយ តែក៏ឃើញមានប្រើនៅ ក្នុងសង្គមតូចៗ ដូចជា សមាគមន៍ សហាគមន៍ ឬអង្គការនានាផងដែរ ។

២-ប្រជាធិបតេយ្យដោយតំណាង (Representative Democracy) មានន័យថា គឺពលរដ្ឋជ្រើសរើសតំណាង របស់ខ្លួនដែលខ្លួនយល់ឃើញថា មានសមត្ថភាពដើម្បីដឹកនាំរដ្ឋដោយសន្លឹកឆ្នោត ។ ប្រជាធិបតេយ្យបែបនេះ គឺឲ្យតំលៃខ្លាំងណាស់ទៅលើបុគ្គលដែលមានសុឆន្ទៈ មានសុទិដ្ឋិនិយម មានទស្សនៈវិស័យល្អ មានសមត្ថភាព ថែមទាំងឲ្យតំលៃទៅលើសិទ្ធិសេរីភាព កម្មសិទ្ធិឯកជនផងដែរ ។

**ចំនុចសំគាល់របស់វា ក៏គឺនៅត្រង់**

-ពហុបក្ស (Multi-parties)

-ការបោះឆ្នោត

-ការកំណត់អាណត្តិ

-គោរពសម្លេងភាគច្រើន

-ការបែងចែកអំណាច

-មួយនាក់មួយសន្លឹក

-មិនបន្លំសន្លឹកឆ្នោត

-ជ្រើសរើសម្នាក់ក្នុងចំណោមគណបក្សដែលឈ្នះឆ្នោត

-គាំទ្រឲ្យមានទីផ្សារសេរី ។

**ពហុបក្ស** មានន័យថា គណបក្សមានចាប់ពីពីរគណៈបក្សឡើងទៅ ហើយគណបក្សទាំងអស់មានការប្រកួតប្រជែងគ្នានៅក្នុងរង្វង់ច្បាប់ ។

**ការបោះឆ្នោត** មានន័យថា សង្គម ឬរដ្ឋាភិបាលនោះ មានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ឃុំ សង្កាត់ ទាំងអស់។ កាលណាមានការបោះឆ្នោតទូលំទូលាយអញ្ចឹង នេះហើយជាលក្ខណៈនៃប្រជាធិបតេយ្យ ឬក៏ប្រើពាក្យមួយថា Democratization ភាសាខ្មែរថា ប្រជាធិបតេយ្យភាវូបនីយកម្ម ។

**ការកំណត់អាណត្តិ** មានន័យថា បីឆ្នាំ បួនឆ្នាំ ឬ ប្រាំឆ្នាំ ។ល។ មានការបោះឆ្នោតសារជាថ្មី ។

**គោរពសម្លេងភាគច្រើន** មានន័យថា រាល់កិច្ចការនយោបាយ កិច្ចការធំរបស់ជាតិត្រូវបានសម្រេចដោយមតិភាគច្រើន គឺចង់និយាយថា ៥០+១ ។

**មានការបែងចែកអំណាច** មានន័យថា មានការបែងចែកអំណាចដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

**មួយនាក់មួយសន្លឹក** មានន័យថា ប្រជាពលរដ្ឋមួយនាក់ មានសិទ្ធិជ្រើសរើសអ្នកតំណាង ឬបោះឆ្នោតឲ្យបេក្ខជន ឬបេក្ខនារីទាំងនោះ បានតែមួយសម្លេង ឬមួយសន្លឹកប៉ុណ្ណោះ ។

**មិនបន្លំសន្លឹកឆ្នោត** មានន័យថា ការគណនាសម្លេងឆ្នោត ត្រូវសុក្រឹតភាព ដោយជៀសវាងជាខាច់ខាតនូវការបំភាន់ ក្លែងបន្លំ និងត្រូវតែគេចឲ្យផុតនូវរាល់អគតិ គឺការរាប់សម្លេងឆ្នោត មានភាពទៀងត្រង់ មិនលំអៀង ។

**ជ្រើសរើសម្នាក់ក្នុងចំណោមគណបក្សដែលឈ្នះឆ្នោត** មានន័យថា សមាជិកក្នុងបក្ស ដែលឈ្នះឆ្នោតទាំងអស់ ត្រូវជ្រើសរើសម្នាក់ ដែលមានសុឆន្ទៈ មនោគតិ ឧត្តមគតិ មានវិចារណញ្ញាណ មានទស្សនវិស័យល្អ គិតបានល្អ ជាវាគ្មិន មានវោហារស័ព្ទ ប្រសប់ជានិយាយ ថែមទាំងជាបុគ្គលដែលខ្មីឃ្មាត ឧស្សាហ៍ និងសកម្មក្នុងកិច្ចការបក្ស និងសាធារណប្រយោជន៍ទៀតផង ពោលគឺជាបុគ្គលដែល «គិតយ៉ាងណា និយាយយ៉ាងណា ធ្វើយ៉ាងនោះ» ឲ្យធ្វើឯកភាពជានាយករដ្ឋមន្ត្រី ។

**គាំទ្រឲ្យមានទីផ្សារសេរី** មានន័យថា ជាទីផ្សារសម្រាប់សាធារណជន ដើម្បីលក់-ទិញ-ដូរ គឺជាទីផ្សារដែលមានការបើកចំហរ ។ល។ ទីផ្សារនេះ គឺឲ្យតំលៃទៅលើបុគ្គល ឬមូលធនបុគ្គលទាំងក្នុង និងក្រៅស្រុក ។

ចំណុចទាំងនេះហើយ គឺជាចំណុចសម្គាល់ថា (រដ្ឋមួយ សង្គមមួយ ឬក៏រដ្ឋាភិបាលមួយកំពុងតែដើរតាមផ្លូវ) ប្រជាធិបតេយ្យពិត ។

## លក្ខណៈរបស់ ខ្មែរក្រហម

# ដើមកំណើតនៃពាក្យ “ខ្មែរក្រហម”



***សាឡុត ស*** *ហៅ          លេខាបក្សកុម្មុយនិស្ត*
*និងជានាយករដ្ឋមន្ត្រីនៃកម្ពុជាប្រជាធិបតេយ្យ*

ពាក្យថា “**ខ្មែរក្រហម**” ត្រូវបានប្រើជាដំបូងដោយសម្តេច នរោត្តម សីហនុ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៥០ សម្តេច នរោត្តម សីហនុ ដែលជាប្រមុខដឹកនាំចលនាសង្គមរាស្ត្រនិយម បានធ្វើការបែងចែកខ្មែរជាបីពណ៌ ដោយយោងទៅតាមនិន្នាការនយោបាយរបស់ពួកគេ គឺ “ខ្មែរស” សំដៅលើខ្មែរអ្នករាជានិយម “ខ្មែរខៀវ” ជាខ្មែរអ្នកសាធារណរដ្ឋនិយម និង “ខ្មែរក្រហម” គឺក្រុមខ្មែរកុម្មុយនិស្តនិយម។ ក៏ប៉ុន្តែ ពីដំបូង ពាក្យថា “ខ្មែរក្រហម” នេះ ត្រូវបានប្រើដោយសំដៅលើក្រុមឆ្វេងនិយម នៅក្នុងចលនាសង្គមរាស្ត្រនិយមរបស់ព្រះអង្គផ្ទាល់។

គួររំឭកថា នៅពេលនោះ ក្រុមខ្មែរកុម្មុយនិស្តនៅមិនទាន់ជាកម្លាំងនយោបាយសំខាន់ប៉ុន្មានទេ។ ខ្មែរកុម្មុយនិស្តមួយចំនួន ដូចជា ខៀវ សំផន

ហ៊ូ នឹម និង ហ៊ូ យន់ ជាដើម នៅធ្វើនយោបាយក្នុងចលនាសង្គមរាស្ត្រនិយម ហើយខ្លះថែមទាំងធ្លាប់ត្រូវបានតែងតាំងឲ្យកាន់តំណែងនៅក្នុងរដ្ឋាភិបាលទៀតផង។

យោងតាមឯកសាររបស់ក្រសួងការបរទេសបារាំង នៅរវាងឆ្នាំ១៩៦០ និងឆ្នាំ១៩៦២ ពាក្យ "ខ្មែរក្រហម" ត្រូវបានគេប្រើម្តងម្កាល ជំនួសពាក្យ "ខ្មែរវៀតមិញ" ដែលគេធ្លាប់ប្រើសំដៅលើក្រុមខ្មែរកុម្មុយនិស្ត បែកចេញពីបក្សកុម្មុយនិស្តឥណ្ឌូចិន។

យោងតាមលោក Raoul JENNAR ក្នុងសៀវភៅ ដែលមានចំណងជើងថា "Les Clés du Cambodge" គឺនៅថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ១៩៦៦ ទើបឈ្មោះ "ខ្មែរក្រហម" ត្រូវបានសម្តេច នរោត្តម សីហនុ ប្រើដោយសំដៅច្បាស់មែនទែនលើចលនាកុម្មុយនិស្តខ្មែរជាទូទៅ ទាំងនៅក្នុង និងក្រៅសង្គមរាស្ត្រនិយម។

### ខ្មែរក្រហម និងបក្សកុម្មុយនិស្តកម្ពុជា

ការណ៍ដែលសម្តេច នរោត្តម សីហនុ លាបពណ៌ក្រហមដល់ចលនាកុម្មុយនិស្តខ្មែរបែបនេះ ព្រោះពណ៌ក្រហម គឺជាពណ៌តំណាងទង់បដិវត្តន៍កុម្មុយនិស្ត។ ម្យ៉ាងទៀត សម្រាប់ប្រជាជនកម្ពុជា ពណ៌ក្រហម គឺជាពណ៌តំណាងអំពីការបង្ហូរឈាម។

ក៏ប៉ុន្តែ មេដឹកនាំខ្មែរកុម្មុយនិស្ត មិនដែលទទួលយកឈ្មោះជាខ្មែរក្រហមនេះទេ។ ជាទូទៅ ពួកខ្មែរក្រហមមិនចូលចិត្តប្រើពាក្យថា "ខ្មែរ" នេះផងទេ។ ពួកគេច្រើនតែប្រើពាក្យថា "កម្ពុជា" ជំនួសវិញ។

មេដឹកនាំកម្ពុជាប្រជាធិបតេយ្យមិនទទួលស្គាល់ខ្លួនឯងថាជា "ខ្មែរក្រហម" តាមឈ្មោះ ដែលសម្តេច នរោត្តម សីហនុ បានដាក់ឲ្យក៏ពិតមែន ប៉ុន្តែ ពួកគេតែងតែបានអះអាងដោយចំហថា បដិវត្តន៍របស់ពួកគេ គឺជាបដិវត្តន៍ "ក្រហមឆ្អិនឆ្អៅ"។

ក្រហម គឺជាពណ៌នៃទង់ជាតិរបស់កម្ពុជាប្រជាធិបតេយ្យ។ ហើយនៅក្នុងភ្លេងជាតិរបស់របបនេះ ក៏មានលើកឡើងជាច្រើនសាដែរអំពីពណ៌ក្រហម ដែលជាពណ៌តំណាងបដិវត្តន៍ និងតំណាងឈាមដែលហូរក្នុងការធ្វើបដិវត្តន៍នេះ។

យោងតាមលោក Ben Kiernan ក្នុងសៀវភៅដែលមានចំណងជើងថា "Le Génocide au Cambodge" ប៉ុល ពត បានលើកឡើងអំពីការបង្កើតរដ្ឋាភិបាលមួយ ដែលមានលក្ខណៈ "ក្រហមសុទ្ធសាធ" បន្ទាប់ពីសម្តេច នរោត្តម សីហនុ លាលែងពីតំណែងជាប្រមុខរដ្ឋ នៅខែមេសា ឆ្នាំ១៩៧៦។

យោងតាមឯកសាររបស់សារព័ត៌មាន BBC នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៨ វិទ្យុរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានផ្សាយអំពីការប្តេជ្ញាចិត្តក្នុងការបន្តបដិវត្តន៍របស់ខ្លួន ហើយថានឹងរក្សាបដិវត្តន៍នោះ "ឲ្យនៅក្រហមជានិច្ច ដោយមិនឲ្យអ្នកណាមកប្តូរពណ៌នេះបានទេ"។

សរុបសេចក្តីមក មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបដិសេធឈ្មោះជា "ខ្មែរក្រហម" តែបានប្រកាសជាចំហទទួលស្គាល់ថាបដិវត្តន៍របស់ពួកគេជា "បដិវត្តន៍ក្រហម" ហើយថែមទាំងប្តេជ្ញាយ៉ាងដាច់អហង្ការរក្សាពណ៌បដិវត្តន៍របស់ពួកគេឲ្យនៅក្រហមជានិច្ចនិរន្តន៍ទៀតផង។

## នយោបាយរបស់ខ្មែរក្រហម

យោងតាមលោក Raoul Jennar នៅចន្លោះពីថ្ងៃទី២០ ដល់ថ្ងៃទី២៥ ឧសភា ឆ្នាំ១៩៧៥ ប៉ុល ពត និង នួន ជា បានប្រកាសឲ្យដឹងនូវគោលនយោបាយសំខាន់ៗចំនួន៨ចំណុច នៃរបបគ្រប់គ្រងថ្មីនេះ។ គោលនយោបាយទាំងនោះរួមមាន៖

**១-ជម្លៀសប្រជាជនចេញពីទីក្រុង** ហើយប្រជាជនត្រូវបែងចែកជាពីរប្រភេទ គឺប្រជាជនដែលរស់នៅក្នុងតំបន់រំដោះមុនថ្ងៃ១៧ មេសា ដែលគេឲ្យឈ្មោះថា "**ប្រជាជនចាស់**" និងប្រជាជនដែលទើបតែជម្លៀសចេញពីទីក្រុង

ក្រោយថ្ងៃ១៧ មេសា ដែលគេឲ្យឈ្មោះថា "**ប្រជាជនថ្មី**" ឬ "**ពួក១៧ មេសា**" ។

**២-លុបបំបាត់ចោលទាំងស្រុងនូវសេដ្ឋកិច្ចទីផ្សារសេរី។**

**៣-លុបបំបាត់ចោលនូវការចាយលុយ។**

**៤-ព្រះសង្ឃទាំងអស់ត្រូវចាប់ផ្សឹក ហើយបញ្ជូនឲ្យទៅធ្វើស្រែ។**

**៥-សម្លាប់ចោលទាំងអស់រាល់មន្ត្រីដែលធ្វើការឲ្យរបបលន់ នល់។**

**៦-បង្កើតជាសហករណ៍នៅទូទាំងប្រទេស។**

**៧-បណ្តេញជនជាតិវៀតណាមឲ្យអស់ពីប្រទេសកម្ពុជា។**

**៨-ដាក់ពង្រាយកងទ័ពនៅតាមព្រំដែន ជាពិសេស ព្រំដែនវៀតណាម។**

### មនោគមន៍វិជ្ជាខ្មែរក្រហម

ពួកខ្មែរក្រហមមានមហិច្ឆតា ចង់ឲ្យបដិវត្តន៍របស់ពួកគេមានលក្ខណៈពិសេសខុសពីគេ ហើយអស្ចារ្យជាងគេ ដោយមិនយកគំរូតាមបដិវត្តន៍របស់ប្រទេសណាមួយ។ ក៏ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ គេអាចសង្កេតឃើញយ៉ាងច្បាស់ថា បដិវត្តន៍របស់ខ្មែរក្រហម មានលក្ខណៈស្រដៀងគ្នាច្រើននឹងបដិវត្តន៍របស់ម៉ៅ សេទុងនៅប្រទេសចិន ក្នុងទសវត្សរ៍ឆ្នាំ៦០។

ទីមួយ ពួកខ្មែរក្រហមប្រកាន់យកនូវទស្សនៈ "សមភាពនិយម" (ជាភាសាបារាំងថា égalitarisme) ពោលគឺ ប្រជាជនមានឋានៈស្មើគ្នាទាំងអស់ គ្មានអ្នកក្រ គ្មានអ្នកមាន គ្មានអ្នកជិះជាន់គេ និងអ្នកដែលត្រូវគេជិះជាន់។ អ្នកជំនួញ មន្ត្រីរាជការ និងប្រជាជនដែលនៅទីក្រុង ត្រូវបានជម្លៀសដោយបង្ខំឲ្យទៅនៅជនបទ ដើម្បីប្រកបការងារស្មើភាពគ្នា គឺការបង្កបង្កើនផលជាលក្ខណៈសមូហភាព។ ចំណែកផលដែលទទួលបានវិញ ក៏ត្រូវបែងចែកដោយស្មើភាពដែរ ពោលគឺ ម្នាក់ៗទទួលបាននូវរបបចំណីអាហារ និងវត្ថុប្រើប្រាស់ស្មើៗគ្នា។ កម្មសិទ្ធិឯកជនត្រូវបានលុបបំបាត់ចោល។ ដូចគ្នាដែរ ចំពោះរូបិយប័ណ្ណ ព្រោះពួកខ្មែរក្រហមយល់ថា ការចាយលុយគឺជាកត្តា

ដែលនាំឲ្យមានការកេងប្រវ័ញ្ច មានអ្នកក្រ និងអ្នកមាន។ សូម្បីតែការប្រើភាសាហៅគ្នាក៏បង្ហាញពីភាពស្មើគ្នាដែរ។ ជាទូទៅ គេហៅគ្នាថា "មិត្ត" ឬ "សមមិត្ត"។ ក៏ប៉ុន្តែ ជារឿងដែលគួរឲ្យហួសចិត្តបំផុតនោះ គឺគេសង្កេតឃើញថា ក្រោមរបបសមភាពនិយមនេះ ប្រជាជនកម្ពុជាត្រូវបានបែងចែកជាពីរឋានៈខុសគ្នាស្រឡះ គឺ "ប្រជាជនចាស់" សំដៅលើអ្នកដែលរស់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម តាំងពីមុនឆ្នាំ១៩៧៥ និង "ប្រជាជនថ្មី" ឬ "ពួក១៧មេសា" សំដៅលើប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុង ក្រោយថ្ងៃ១៧ មេសា ១៩៧៥។

ទីពីរ ពួកខ្មែរក្រហមមានគំនិតបែបស្រមើស្រមៃចង់ឲ្យសង្គមខ្មែរក្លាយជាសង្គមស្អាតស្អំឥតខ្ចោះ គ្មានអយុត្តិធម៌ ជាសង្គមប្រកបដោយភាពរុងរឿងឯករាជ្យម្ចាស់ការ។ គឺជាគំនិតស្រមើស្រមៃចង់បានហួសពីការពិត ហួសពីសមត្ថភាព ដែលអាចធ្វើទៅបាន (ជាភាសាបារាំងថា "utopisme")។

ក្រៅពីមនោគមន៍វិជ្ជាកុម្មុយនិស្តបែបម៉ៅនិយម គេសង្កេតឃើញថាពួកខ្មែរក្រហមក៏មានទស្សនៈបែបជាតិនិយមជ្រុលផងដែរ។ ពួកមេដឹកនាំខ្មែរក្រហមយល់ថា ជនជាតិខ្មែរដើមជាជនជាតិខ្លាំងពូកែ ស្អាតស្អំ គ្មានការកេងប្រវ័ញ្ច និងការជិះជាន់គ្នា។ ការលាយឡំជាតិសាសន៍ជាមួយជនជាតិផ្សេងទៀត ដូចជា ចាម ចិន វៀតណាមជាដើម បានធ្វើឲ្យជាតិខ្មែរធ្លាក់ចុះទន់ខ្សោយ។ ហេតុដូចនេះហើយ បានជាក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមជនបរទេសត្រូវទទួលរងនូវការធ្វើទុក្ខបុកម្និញយ៉ាងខ្លាំង។ ភាសាវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ របស់បរទេសត្រូវបានហាមឃាត់ដាច់ខាត។ សូម្បីតែអ្នកណាត្រូវរៀបការជាមួយអ្នកណាក៏អង្គការជាអ្នកសម្រេចឲ្យដែរ។ គ្មានអ្នកណាម្នាក់មានសិទ្ធិជ្រើសរើសគូស្រករដោយចិត្តឯងបានទេ។

សរុបសេចក្ដីមក ខ្មែរក្រហមប្រកាន់យកនូវមនោគមន៍វិជ្ជាកុម្មុយនិស្តម៉ៅនិយមផង និងបែបជាតិនិយមជ្រុលផង៕

# ជីវប្រវត្តិរបស់ ប៉ុល ពត

ជីវប្រវត្តិរបស់ ប៉ុល ពត



ប៉ុល ពត ត្រូវបានគេស្គាល់ថាជាបងទី១ ក្នុងចំណោមមេដឹកនាំខ្មែរក្រហម។ សូម្បីតែពេលនេះ ប៉ុល ពត បានស្លាប់បាត់ទៅហើយក្តី ក៏ឈ្មោះ ប៉ុល ពត នៅតែផ្សារភ្ជាប់នឹងរបបខ្មែរក្រហមជានិច្ច។ បើកាលណាគេនិយាយអំពីខ្មែរក្រហម មនុស្សដែលគេនឹកឃើញមុនគេ គឺ ប៉ុល ពត។ ប្រជាជនកម្ពុជាទូទៅតែងតែហៅរបបកម្ពុជាប្រជាធិបតេយ្យថាជា "របបប៉ុលពត" ទៀតផង។ តើប៉ុល ពត ជានរណា?

ប៉ុល ពត គឺជាលេខាបក្សកុម្មុយនិស្តកម្ពុជា ដែលជាតំណែងខ្ពស់បំផុតនៅក្នុងបក្ស និងជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលគេស្គាល់ថាជា "របបខ្មែរក្រហម" ឬ "របបប៉ុល ពត"។ ប៉ុល ពត គឺជាមនុស្សដ៏អាថ៌កំបាំងម្នាក់ ដែលចំណាយពេលភាគច្រើននៃជីវិតរបស់គាត់ រស់ក្នុងការលាក់កំបាំង។ សូម្បីតែឈ្មោះ និងថ្ងៃខែឆ្នាំកំណើតក៏ប៉ុល ពត បានផ្លាស់ប្តូរដែរ។

ប៉ុល ពត តាមពិតមានឈ្មោះដើមថា សាឡុត ស កើតនៅភូមិព្រែកស្បូវ ក្នុងខេត្តកំពង់ធំ។ គេដឹងថា ប៉ុល ពត ស្លាប់ នៅថ្ងៃទី ១៥ ខែមេសា ឆ្នាំ១៩៩៨។ ក៏ប៉ុន្តែ ប៉ុល ពត កើតនៅថ្ងៃណា ខែណា ឆ្នាំណា នៅតែជាបញ្ហាមិនច្បាស់លាស់ដដែល។ យោងតាមវិទ្យុជាតិកម្ពុជាប្រជាធិបតេយ្យ ដែលបានផ្សាយនៅឆ្នាំ១៩៧៧ ប៉ុល ពត កើតនៅឆ្នាំ១៩២៥។ ក៏ប៉ុន្តែយោងតាមឯកសារជាច្រើនដែលអាណាព្យាបាលបារាំងបានតម្កល់ទុកនៅឆ្នាំ១៩៥០ ប៉ុល ពតឬសាឡុត ស កើតនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩២៨។ ឯប៉ុល ពត ខ្លួនឯងបានអះអាងថ្ងៃខែឆ្នាំកំណើតពិតរបស់គាត់ គឺខែមករា ឆ្នាំ១៩២៥ ប៉ុន្តែ បានបន្ថយអាយុពាឆ្នាំ ដោយចុះក្នុងបញ្ជីជាតិថាកើតនៅឆ្នាំ១៩២៨វិញ។

សាឡុត ស កើតក្នុងគ្រួសារត្រកូលកសិករស្តុកស្តម្ភមួយនៅខេត្តកំពង់ធំ។ ឪពុករបស់ សាឡុត ស ឈ្មោះ ប៉ែន សាឡុត ម្តាយឈ្មោះ សុក ណែម។ សាឡុត ស មានបងប្អូនទាំងអស់៩នាក់ ក្នុងនោះប្រុស៧នាក់ និងស្រី២នាក់។ សាឡុត ស គឺជាកូនទី៨។

យោងតាមលោក **David Chandler** គ្រួសាររបស់ សាឡុត ស មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះបរមរាជវាំង។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩២០ បងស្រីជីដូនមួយម្នាក់របស់ សាឡុត ស ឈ្មោះ មាយ គឺជាអ្នករាំរបាំព្រះរាជទ្រព្យប្រចាំព្រះបរមរាជវាំង។ ក្រោយមក មាយ ក៏បានក្លាយជាស្នំឯករបស់ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីវង្ស ហើយទទួលបានតំណែងជា ឃុនព្រះម្នាង ដែលមានអំណាចត្រួតលើស្រីទាំងអស់នៅក្នុងវាំង។

បងប្រុសច្បងរបស់ សាឡុត ស ឈ្មោះ សាឡុត សួង ក៏ជាបុគ្គលិកម្នាក់បម្រើការនៅក្នុងការិយាល័យពិធីការនៃព្រះបរមរាជវាំងដែរ។ មិនយូរប៉ុន្មានក្រោយមក ប្អូនស្រីរបស់ សាឡុត ស ឈ្មោះ សារឿន ក៏បានចូលមកបម្រើការក្នុងក្រុមរបាំព្រះរាជ

ទ្រព្យ ហើយបានក្លាយជាស្នំឯករបស់ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ដូច មាយ ដែរ។

នៅឆ្នាំ១៩៣៤ សាឡុត ស ដែលកាលនោះមានអាយុ៦ឆ្នាំ (បើគិតតាមថ្ងៃខែឆ្នាំកំណើតដែលបានចុះក្នុងបញ្ជីជាតិ) និងបងប្រុសម្នាក់ទៀត ឈ្មោះ សាឡុត ឆាយ ត្រូវបានគ្រួសារបញ្ជូនពីកំពង់ធំឲ្យមករស់នៅភ្នំពេញជាមួយ មាយ និង សួង ដែលជាបង។ មិនយូរប៉ុន្មានក្រោយពីមកដល់ភ្នំពេញ សាឡុត ស ក៏បានទៅបួសរៀនធម៌ និងភាសាខ្មែរនៅវត្តបុទមវត្តី ដែលស្ថិតនៅជាប់នឹងព្រះបរមរាជវាំង។ គួរបញ្ជាក់ថា នៅពេលនោះ ប្រទេសកម្ពុជាកំពុងស្ថិតក្រោមអាណាព្យាបាលបារាំង ហើយនៅតាមសាលារៀនរបស់រដ្ឋ គេតម្រូវឲ្យរៀនជាភាសាបារាំង។

នៅក្នុងបទសម្ភាសន៍ជាមួយអ្នកកាសែតបរទេស ពេល កំពុងកាន់តំណែងជានាយករដ្ឋមន្ត្រី ប៉ុល ពតបានរៀបរាប់យ៉ាងដូចនេះថា៖ *"ខ្ញុំជាកូនចៅរបស់កសិករម្នាក់។ ពីតូច ធ្លាប់រួមរស់ ធ្វើការងារស្រែចម្ការជាមួយឪពុកម្ដាយ។ ហើយក្រោយមក មកនៅវត្ត ជាទំនៀមទម្លាប់ ដើម្បីរៀនសូត្រអក្សរ។"*

ក្រោយពីបានបួសអស់ប៉ុន្មានខែមក នៅឆ្នាំ១៩៣៦ សាឡុត ស ក៏បានចូលរៀននៅសាលាបឋមសិក្សាកាតូលិកមួយ នៅជិតព្រះបរមរាជវាំង។ សិស្សនៅសាលានោះ ច្រើនតែជាកូនមន្ត្រីរាជការ ឬអ្នកមានឋានៈធំដុំ ហើយថ្លៃសាលានោះទៀតសោត ក៏មានតម្លៃខ្ពស់ដែរ។

នៅក្នុងអំឡុងពេលនោះ មានព្រឹត្តិការណ៍មួយចំនួនបានកើតឡើងដែលអាចជះឥទ្ធិពលដល់គំនិតរបស់ សាឡុត ស ជាពិសេសគំនិតបែបជាតិនិយម។

នៅពេលដែល សាឡុត ស ទើបតែបានចូលរៀននៅសាលាបឋមសិក្សា ស៊ីន ង៉ុកថាញ់ ស៊ឹម វ៉ា និង ប៉ាច ឈឿន ដែលធ្វើការនៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតក្នុងក្រុងភ្នំពេញ បានទទួលការអនុញ្ញាតពីអាជ្ញាធរបារាំង ឲ្យបោះផ្សាយកាសែតជាភាសាខ្មែរមួយឈ្មោះ “នគរវត្ត” ដែលជាកាសែតភាសាខ្មែរលើកដំបូងបង្អស់ នៅប្រទេសកម្ពុជា។ កាសែត នគរវត្ត មានចុះផ្សាយនូវអត្ថបទវិចារណកថាជាច្រើន ដែលបង្ហាញពីគំនិតជាតិនិយម។ សាឡុត ស ដែលរស់នៅជាមួយបង ប្រហែលជាបានអានកាសែតនេះជាប្រចាំ ពីព្រោះថា បើយោងតាមលោក **David**

**Chandler** មាឃ និង សួង ដែលត្រូវជាបងរបស់ សាឡុត ស បានជាវកាសែត នគរវត្ត មកអានជាប្រចាំ។

ព្រឹត្តិការណ៍សំខាន់មួយទៀត គឺនៅពេលដែល សាឡុត ស រៀន ជិតចប់បឋមសិក្សា នៅចន្លោះឆ្នាំ១៩៤០ និងឆ្នាំ១៩៤១ បារាំង ដែលច្បាំងចាញ់អាល្លឺម៉ង់ នៅក្នុងសង្គ្រាមលោកលើកទីពីរ ក៏ បានយល់ព្រមឲ្យថៃកាត់យកទឹកដីខេត្តបាត់ដំបង និងសៀមរាប របស់ខ្មែរទៅគ្រប់គ្រងដែលជាហេតុបណ្តាលឲ្យប្រជាជនកម្ពុជា មានកំហឹងយ៉ាងខ្លាំង។ សូម្បីតែព្រះបាទ មុនីវង្ស ក៏ខ្វល់នឹងការ បាត់បង់ទឹកដីនេះយ៉ាងខ្លាំងដែរ រហូតសម្រេចព្រះទ័យចាកចេញ ពីព្រះបរមរាជវាំងទៅគង់នៅខេត្តកំពង់ឆ្នាំង ហើយបដិសេធ ឈប់និយាយភាសាបារាំងរហូតដល់ព្រះអង្គចូលទិវង្គត នៅឆ្នាំ ១៩៤១។

ទំនងជាហេតុការណ៍ទាំងពីរនេះហើយ ដែលបានជះឥទ្ធិពលដល់ គំនិតរបស់សាឡុត ស ដែលនៅជាកុមារនៅឡើយ ឲ្យមានគំនិត ស្អប់បរទេស និងមានគំនិតជាតិនិយម។

នៅឆ្នាំ១៩៤២ សាឡុត ស បានជាប់ឈ្មោះក្នុងចំណោមសិស្ស២០នាក់ ដែលត្រូវបានជ្រើសរើសឲ្យទៅរៀននៅអនុវិទ្យាល័យមួយឈ្មោះ "អនុវិទ្យាល័យព្រះសីហនុ" ដែលបារាំងទើបនឹងបង្កើត នៅខេត្តកំពង់ចាម។

នៅថ្ងៃទី២០ កក្កដា ឆ្នាំ១៩៤២ នៅទីក្រុងភ្នំពេញ បាតុកម្មដ៏ធំមួយត្រូវបានរៀបចំឡើងប្រឆាំងនឹងបារាំង។ បាតុកម្មនេះកើតឡើងក្រោយពីអាជ្ញាធរបារាំងបានចាប់ខ្លួនព្រះសង្ឃពីរអង្គ គឺអាចារ្យ ហែមចៀវ និង នួន ឌួង ដែលបានទេសនាប្រឆាំងនឹងបារាំង។ បាតុកម្មនេះត្រូវបានដឹកនាំដោយ សឺន ង៉ុកថាញ់ និង ប៉ាច ឈឿន ហើយមានអ្នកចូលរួមរាប់ពាន់នាក់ ក្នុងនោះមានព្រះសង្ឃប្រមាណ៥០០អង្គផង។ ដោយយើងមិនដឹងច្បាស់ អំពីថ្ងៃដែល សាឡុត ស ចាកចេញពីភ្នំពេញទៅកំពង់ចាម យើងមិនអាចដឹងបានទេថា តើ សាឡុត ស បានចូលរួមក្នុងបាតុកម្មនេះដែរឬអត់?

នៅឯអនុវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម សាឡុត ស បានជួបជាមួយ ហ៊ូ នឹម ហ៊ូ យន់ និង ខៀវ សំផន ដែលរៀននៅទីនោះដែរ។ អ្នកទាំងនេះសុទ្ធតែជាកូនអ្នកចេះដឹង ហើយសុទ្ធតែជា

អ្នករៀនពូកែ ដែលក្រោយមកសុទ្ធតែបានក្លាយជាមេដឹកនាំសំខាន់ៗរបស់ចលនាខ្មែរក្រហម។ ក៏ប៉ុន្តែ មិត្តភក្តិជិតស្និទ្ធបំផុតរបស់ សាឡុត ស នៅពេលនោះ គឺ លន់ ណុន ប្អូនប្រុសរបស់ លន់ នល់។ ប្រហែលជាដោយសារតែទំនាក់ទំនងមិត្តភាពជាមួយមេដឹកនាំខ្មែរក្រហមនេះហើយ បានជានៅឆ្នាំ១៩៧៥ លន់ ណុន មិនព្រមចាកចេញពីទីក្រុងភ្នំពេញប្រហែលជាមកពីគិតថា ពួកមេដឹកនាំខ្មែរក្រហមអាចយោគយល់ដល់មិត្តចាស់។ ក៏ប៉ុន្តែ លន់ណុន ត្រូវបានទាហានខ្មែរក្រហមសម្លាប់ចោលភ្លាមៗ ក្រោយពីដណ្តើមកាន់កាប់ទីក្រុងភ្នំពេញ។

និយាយអំពីអត្តចរិតរបស់ សាឡុត ស វិញ បើយោងតាមសិស្សដែលរៀនជាមួយ សាឡុត ស នៅអនុវិទ្យាល័យកំពង់ចាម សាឡុត ស គឺជាមនុស្សសាមញ្ញម្នាក់ មិនសូវនិយាយស្តីច្រើន ចូលចិត្តលេងបាល់ទាត់ និងបាល់បោះ។ ជាមនុស្សរួសរាយ និងចេះគួរសម ហើយជាមនុស្សមិនបង្ហាញពីមហិច្ឆតាចង់ធ្វើអ្វីឲ្យបានធំដុំនោះទេ។ សាឡុត ស ខ្លួនឯងក៏ធ្លាប់បានអះអាងស្រដៀងគ្នានេះដែរ។

យោងតាមលោក **David Chandler** សាឡុត ស រៀនមិនពូកែនោះទេ គឺរៀនបានត្រឹមតែជាប់មធ្យមភាគប៉ុណ្ណោះ ហើយពេលខ្លះមិនបានទាំងជាប់មធ្យមភាគផង។

នៅឆ្នាំ១៩៤៧ សាឡុត ស បានបញ្ចប់ការសិក្សានៅអនុវិទ្យាល័យកំពង់ចាម។ ផ្ទុយពីសិស្សរួមសាលាមួយចំនួន ដូចជា ខៀវ សំផន ជាដើម ដែលបានចូលរៀននៅ វិទ្យាល័យស៊ីសុវត្ថិដែលជាវិទ្យាល័យដ៏ល្បីល្បាញនៅភ្នំពេញ សាឡុត ស បានទៅចូលរៀននៅសាលាបច្ចេកទេសមួយ នៅក្នុងខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ដោយយកជំនាញខាងជាងដែក។ បើតាមលោក **David Chandler** សាឡុត ស ទៅរៀននៅសាលាបច្ចេកទេសនេះ មិនមែនដោយសារតែគាត់ស្រឡាញ់ចូលចិត្តមុខជំនាញនេះទេ ប៉ុន្តែ មកពីគាត់ប្រឡងចូលវិទ្យាល័យស៊ីសុវត្ថិបានជាប់។

ទោះជាមិនបានចូលរៀននៅវិទ្យាល័យស៊ីសុវត្ថិក៏ពិតមែន តែសាឡុត ស បានក្លាយជាមិត្តជិតស្និទ្ធជាមួយនឹងសិស្សម្នាក់មកពីវិទ្យាល័យស៊ីសុវត្ថិ គឺ អៀង សារី។ យោងតាមលោកកេង វណ្ណសាក់ ដែលជាមន្ត្រីថ្នាក់ដឹកនាំគណបក្សប្រជាធិបតេយ្យ សាឡុត ស និង អៀង សារី បានចូលរួមយ៉ាងសកម្ម ជួយគណបក្ស

ប្រជាធិបតេយ្យ ក្នុងពេលបោះឆ្នោតជាតិឆ្នាំ១៩៩៧។ នៅពេលនោះ គណបក្សប្រជាធិបតេយ្យ ដែលមានអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ជាប្រធានបានទទួលជ័យជំនះយ៉ាងលើសលុប ដោយឯណ្តើមបាន ៦០អាសនៈ ក្នុងចំណោមអាសនៈសរុបទាំង ៧៥ នៅរដ្ឋសភា។

នៅឆ្នាំ១៩៤៩ សាឡុត ស បានទទួលអាហារូបករណ៍ ដើម្បីទៅបន្តការសិក្សានៅប្រទេសបារាំង ផ្នែកអេឡិចត្រូនិច។ សំណួរសួរថា ហេតុអ្វីបានជា សាឡុត ស ដែលរៀនមិនសូវពូកែផង តែបែរជាទទួលបានអាហារូបករណ៍ទៅរៀននៅប្រទេសបារាំងបែបនេះ? នេះប្រហែលជាមកពីហេតុផលសំខាន់ពីរ៖

**ទី១** នៅពេលនោះ ក្រសួងអប់រំស្ថិតក្រោមការគ្រប់គ្រងរបស់គណបក្សប្រជាធិបតេយ្យ ដែលឈ្នះឆ្នោត កាលពីឆ្នាំ១៩៤៧។ ប្រហែលជាដោយសារតែ សាឡុត ស បានជួយធ្វើការឃោសនាបោះឆ្នោតឲ្យគណបក្សប្រជាធិបតេយ្យ ទើបរដ្ឋមន្ត្រីក្រសួងអប់រំផ្តល់អាហារូបករណ៍ឲ្យ សាឡុត ស បានទៅរៀននៅបារាំង។

**ទី២** នៅពេលនោះ មិនសូវមានកូនខ្មែរណាមានជំនាញខាងអេឡិចត្រូនិចទេ។ ប្រហែលជាមកពីហេតុនេះហើយបានជាក្រសួងអប់រំបញ្ជូន សាឡុត ស ដែលរៀននៅសាលាបច្ចេកទេសស្រាប់ ឲ្យទៅបន្តការសិក្សាផ្នែកបច្ចេកទេសអេឡិចត្រូនិច នៅប្រទេសបារាំង។

ទោះជាក្នុងហេតុផលណាមួយក៏ដោយ សាឡុត ស បានក្លាយជាសិស្សមួយរូប ក្នុងចំណោមសិស្សពូកែទាំង២១រូប ដែលត្រូវបានរដ្ឋាភិបាលបញ្ជូនទៅរៀននៅប្រទេសបារាំង នៅឆ្នាំ១៩៤៩។ គឺនៅប្រទេសបារាំងនោះហើយ ដែល សាឡុត ស បានក្លាយទៅជាជនកុម្មុយនិស្ត៕